កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# របាយការណ៍អង្កេត ស្តីពីលទ្ធភាពទទួលបាន និងការយល់ដឹងលើថវិកាក្រុង ស្រុក



**បោះពុម្ពដោយ**

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ)

**ការិយាល័យកណ្តាល**

ទីក្រុងបុន និងអ៊ិចប៊ិន ប្រទេសអាល្លឺម៉ង់

**កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល**

| | |
|---|---|
| ការិយាល័យនៅភ្នំពេញ | ការិយាល័យនៅខេត្តបាត់ដំបង |
| ផ្ទះលេខ១៦៤ អេ ផ្លូវ២៧៨ | សាលាខេត្តបាត់ដំបង |
| សង្កាត់បឹងកេងកង ១ | ផ្លូវលេខ ១ ទល់មុខស្ពានចាស់ |
| រាជធានីភ្នំពេញ ប្រទេសកម្ពុជា | ខេត្តបាត់ដំបង ប្រទេសកម្ពុជា |
| ទូរស័ព្ទលេខ៖ +៨៥៥ ២៣ ២១ ៦៧ ៥៦ | ទូរស័ព្ទលេខ៖ +៨៥៥ ៥៣ ៧៣១ ២៦២ |

Facebook: https://www.facebook.com/darprogramme/
Website:  www.giz.de

**អ្នកនិពន្ធ/អ្នកទទួលខុសត្រូវ/អ្នកពិនិត្យឡើងវិញ៖**

អង្គការទិន្នន័យអំពីការអភិវឌ្ឍ ផ្ទះលេខ៤៣ ផ្លូវលេខ២០៨ សង្កាត់បឹងរាំង ខណ្ឌដូនពេញ

**រចនាប្លង់**

អង្គការទិន្នន័យអំពីការអភិវឌ្ឍ រាជធានីភ្នំពេញ

ខេត្តបាត់ដំបង ឆ្នាំ២០២០

# មាតិកា

*បញ្ជីអក្សរកាត់*......4
*1. សេចក្តីសង្ខេបរួម*......6
*2. វិធីសាស្ត្រស្រាវជ្រាវ*......9
2.1. ដំណាក់កាលក្នុងការស្រាវជ្រាវ......9
2.2. យុទ្ធសាស្ត្រជ្រើសរើសសំណាក និងប្រមូលទិន្នន័យ......10
2.2.1. ការស្ទង់មតិប្រជាពលរដ្ឋ......11
2.2.2. កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ (KII)......12
2.2.3. ការពិភាក្សាជាមួយក្រុមគោលដៅ (FGD)......14
2.2.4. សិក្ខាសាលាពិគ្រោះយោបល់......14
*3. លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ*......15
3.1. លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ......15
3.2 កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះនៅរដ្ឋបាលក្រុង ស្រុក......18
*4. ការរកឃើញអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តជាក់ស្តែងចំពោះថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក*......20
4.1. ចំណេះដឹង ឥរិយាបថ និងការអនុវត្តជាក់ស្តែងរបស់ប្រជាពលរដ្ឋ......20
4.2. ចំណេះដឹង ឥរិយាបថ និងការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុក......22
*5. ការរកឃើញស្តីពីការយល់ដឹងលើឧបត្ថម្ភថវិកាប្រចាំឆ្នាំក្រុង ស្រុក*......24
5.1. ការយល់ដឹងរបស់ប្រជាពលរដ្ឋ......24
5.2. ការយល់ដឹងរបស់មន្ត្រីរដ្ឋបាលក្រុង ស្រុក......26
*6. ការរកឃើញស្តីពីការផ្សព្វផ្សាយព័ត៌មានអំពីថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ*......30
*7. ការរកឃើញស្តីពីការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក*......40
*8. អនុសាសន៍*......45
8.1. សម្ភារៈ ឬឯកសារផ្សព្វផ្សាយថ្មី និងយុទ្ធសាស្ត្រក្នុងការផ្សព្វផ្សាយ......45

8.2. ការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ ....................................................53
8.3. ការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលក្រុង ស្រុក....................................................55
8.4. ទម្រង់គំរូថវិកាប្រចាំឆ្នាំក្រុង ស្រុកដែលងាយយល់ ....................................................57
*9. **ឧបសម្ព័ន្ធ**........................................................................................59*

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| **API** | Advocacy and Policy Institute | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ |
| **BMZ** | Federal German Ministry for Economic Cooperation and Development | ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ |
| **BoG** | Board of Governors | គណៈអភិបាល |
| **CAF** | Community Accountability Facilitator | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ |
| **CARE** | Cooperative for Assistance and Relief Everywhere | អង្គការសហករណ៍សម្រាប់ជំនួយគាំទ្រ និងសង្គ្រោះនៅគ្រប់ទីកន្លែង |
| **CSO** | Civil Society Organisation | អង្គការសង្គមស៊ីវិល |
| **DAR** | Decentralisation and Administrative Reform | កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (កម្មវិធីដារ) |
| **D&D** | Decentralisation and De-concentration | ការធ្វើវិមជ្ឈការ និងវិសហមជ្ឈការ |
| **D/M** | District/Municipality | ក្រុង ស្រុក |
| **FGD** | Focus Group Discussion | ការពិភាក្សាជាមួយក្រុមគោលដៅ |
| **GIZ** | Deutsche Gesellschaft für Internationale Zusammenarbeit | អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ |
| **IEC** | Information, Education and Communication | សម្ភារៈព័ត៌មាន អប់រំ និងទំនាក់ទំនង |
| **I-SAF** | Implementation of Social Accountability Framework | ការអនុវត្តក្របខណ្ឌគណនេយ្យសង្គម |
| **KAP** | Knowledge, Attitude and Practices | ចំណេះដឹង  ឥរិយាបថ និងការអនុវត្ត |
| **KII** | Key Informant Interview | កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ |
| **MCS** | Ministry of Civil Service | ក្រសួងមុខងារសាធារណៈ |
| **MEF** | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| **MoEYS** | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| **MoH** | Ministry of Health | ក្រសួងសុខាភិបាល |
| **MoI** | Ministry of Interior | ក្រសួងមហាផ្ទៃ |
| **NCDD** | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| **NCDD-S** | Secretariat of the National Committee for Sub-National Democratic Development | លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

| | | |
|---|---|---|
| **NLC** | National League of Local Councils | សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា |
| **ODC** | Open Development Cambodia | អង្គការទិន្នន័យអំពីការអភិវឌ្ឍ |
| **OL** | Organic Law | ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| **OWSO** | One Window Service Office | ការិយាល័យច្រកចេញចូលតែមួយ |
| **Q&A** | Question and Answer | សំណួរ និងចម្លើយ |
| **RACHA** | Reproductive and Child Health Alliance | អង្គការសម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ |
| **RDA** | Rural Development Association | សមាគមន៍អភិវឌ្ឍជនបទ |
| **RGC** | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| **SK** | STAR Kampuchea | អង្គការស្ដារកម្ពុជា |
| **TI** | Transparency International | អង្គការតម្លាភាពអន្តរជាតិ |
| **VSG** | Village Support Group | អង្គការក្រុមទ្រទ្រង់ភូមិ |
| **WMC** | Women’s Media Centre of Cambodia | មណ្ឌលព័ត៌មានស្ត្រីកម្ពុជា |
| **WP** | Watthnak Pheap | អង្គការវឌ្ឍនភាព |
| **WV** | World Vision | អង្គការទស្សនៈពិភពលោក |

## 1. សេចក្តីសង្ខេបរួម

ជាច្រើនឆ្នាំមកហើយ អំណាចរដ្ឋបាល និងនយោបាយនៅក្នុងប្រទេសកម្ពុជា ភាគច្រើនស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលថ្នាក់កណ្តាល។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលកម្ពុជា កំពុងតែអនុវត្តនូវយុទ្ធសាស្ត្រវិមជ្ឈការ ដែលក្នុងនោះធនធានហិរញ្ញវត្ថុ និងធនធានមនុស្សជាមួយនឹងអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត កំពុងត្រូវបានផ្ទេរជាបណ្តើរៗជូនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ កំណែទម្រង់នេះកំពុងដឹកនាំដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដោយមានក្រសួងសំខាន់ៗមួយចំនួនកំពុងអនុវត្តកិច្ចការងារ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ខ្លួន ក្នុងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកកិច្ចការកំណែទម្រង់វិមជ្ឈការសារពើពន្ធ ហើយក្រសួងមុខងារសាធារណៈទទួលបន្ទុកកិច្ចការកំណែទម្រង់រដ្ឋបាលសាធារណៈ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលបំណង "បង្វិតសេវាសាធារណៈឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ" តាមរយៈការជំរុញឱ្យប្រជាពលរដ្ឋ "បញ្ចេញមតិរបស់ខ្លួនចំពោះអភិបាលកិច្ចមូលដ្ឋាន ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តនានាពាក់ព័ន្ធនឹងជីវភាពរស់នៅរបស់ពួកគេ និងអាចឱ្យរដ្ឋបាលមូលដ្ឋានរបស់ពួកគេមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ចំពោះគោលនយោបាយ សេចក្តីសម្រេច ទង្វើ និងសកម្មភាពផ្សេងៗរបស់ខ្លួន ហើយក៏ឱ្យជ្រាបអំពីរបៀបដែលគេប្រើប្រាស់ ឬមិនប្រើប្រាស់សិទ្ធិអំណាច និងធនធានសាធារណៈ"[1]។ ក្រៅពីនេះ កំណែទម្រង់នេះក៏ដើរតួនាទីជាឧបករណ៍មួយយ៉ាងសំខាន់ក្នុងការពង្រឹងភាពអង់អាចរបស់ស្ត្រី និងក្រុមជនងាយរងគ្រោះ ដែលអាចឱ្យពួកគាត់បានចូលរួម និងមានឥទ្ធិពលលើអភិបាលកិច្ចមូលដ្ឋាន[2]។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះត្រូវបានគេចាប់ផ្តើមអនុវត្តដំបូងនៅថ្នាក់ឃុំ សង្កាត់ក្នុងឆ្នាំ ២០០១ ដោយមានការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។ ជាមួយនឹងក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានពង្រីកកំណែទម្រង់នេះទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត មានដូចជា រាជធានីភ្នំពេញ ខេត្ត ក្រុង ស្រុក និងខណ្ឌ។

កំណែទម្រង់នេះគឺមានបង្កប់នៅក្នុងគោលការណ៍នៃការអភិវឌ្ឍតាមបែបគោលការប្រជាធិបតេយ្យ ដែលជាទស្សនទានស្នូលមួយនៃរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការប្តេជ្ញាចិត្តក្នុង

---

[1] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨), ទំព័រទី ៤

[2] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨), ទំព័រទី ៤

ការលើកកម្ពស់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងផែនការនានារបស់ គ.ជ.អ.ប។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (២០០៨) បានកំណត់អំពីការផ្ទេរការទទួលខុសត្រូវ និងធនធាននានាទៅដល់ក្រុមប្រឹក្សាជាប់ឆ្នោតនៅថ្នាក់ក្រោមជាតិ ដោយមានគោលបំណងចម្បងចំនួនពីរ គឺដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យមូលដ្ឋាន និងចូលរួមចំណែកក្នុងការបង្កើត លើកកម្ពស់ និងធ្វើឱ្យមានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយនិរន្តរភាព។ ច្បាប់នេះបានចែងថា ក្រុមប្រឹក្សាថ្មីត្រូវមានតួនាទីអនុវត្តកិច្ចការចាំបាច់នានា ដើម្បីសម្រេចគោលបំណងក្នុងការបង្កើត ការលើកកម្ពស់ និងការធ្វើឱ្យមានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយនិរន្តរភាព និងដើម្បីបំពេញមុខងារ និងភារកិច្ចដែលបានប្រគល់ និងធ្វើប្រតិភូកម្មទៅក្រុមប្រឹក្សាតាមរយៈច្បាប់នេះ ឬអនុលោមទៅតាមច្បាប់នេះ[3] ដែលជាគោលការណ៍ណែនាំនៅក្នុងរបៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាឆ្អឹងខ្នងរបស់យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជា។

ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តបច្ចុប្បន្ន សមត្ថភាពប្រតិបត្តិរបស់ក្រុង ស្រុក បានដាក់កំហិតលើសមត្ថភាពរបស់ខ្លួន ក្នុងការស្រូបយកការផ្លាស់ប្តូរទាំងអស់ដែលបានរៀបរាប់ខាងលើ។ ភស្តុតាងបានបង្ហាញថា តម្លាភាពថវិកាស្ថិតនៅក្នុងកម្រិតទាបនៅឡើយ ការចូលរួមពីប្រជាពលរដ្ឋនៅមិនទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ ខ្វះយន្តការដើម្បីជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋនៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងការតាមដានលើការប្រើប្រាស់ហិរញ្ញវត្ថុ និងកង្វះសមត្ថភាពខាងផ្នែករដ្ឋបាល។

[3] ច្បាប់រៀបចំអង្គការ, មាត្រា ២៩

*រូបភាព ១.១ រចនាសម្ព័ន្ធរដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*




*ប្រភពព័ត៌មាន៖មេរៀនសម្រាប់ការយល់ដឹង និងការបណ្តុះបណ្តាលស្តីពីច្បាប់រៀបចំអង្គការ (២០១២)*

ក្នុងពេលអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (កម្មវិធីដារ) មានគោលបំណងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើស ក្នុងការផ្តល់សេវាសង្គម និងសេវារដ្ឋបាល ឱ្យប្រកបដោយការសម្របសម្រួលល្អ តម្លាភាព គណនេយ្យភាព និងដោយមានការចូលរួមពីប្រជាពលរដ្ឋ។ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលត្រូវបានអនុវត្តដោយអង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (ជីអាយហ្សិត) និងទទួលបានការគាំទ្រពីក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ។

នៅថ្នាក់ជាតិ កម្មវិធីនេះបានធ្វើកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមុខងារសាធារណៈ និងក្រសួងវិស័យមួយចំនួន មានដូចជាក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យមើលក្របខណ្ឌគតិយុត្តឡើងវិញ និងរៀបចំលិខិតូបករណ៍ និងនីតិវិធីចាំបាច់នានា ដោយផ្អែកលើការអនុវត្តជាក់ស្តែងពីថ្នាក់ក្រោមមូលដ្ឋាន។ នៅថ្នាក់ក្រោមជាតិ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលបានគាំទ្ររដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង ដើម្បីដោះស្រាយបញ្ហាមូលដ្ឋាន និងបង្កើនសមត្ថភាពរបស់បុគ្គលិករដ្ឋបាលនិងក្រុមប្រឹក្សារបស់រដ្ឋបាលទាំងនេះ ក្នុង

គោលបំណងកែលម្អការផ្តល់សេវាសង្គម និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរ។ កត្តានេះនឹងជួយជំរុញឱ្យក្រុមប្រឹក្សាអាចបំពេញតួនាទី ភារកិច្ចថ្មីរបស់ខ្លួន និងពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានកាន់តែប្រសើរ។

របាយការណ៍នេះបង្ហាញពីការរកឃើញនៃការអង្កេតមួយ ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបនឹងគោលបំណងទី៤ នៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ "នៅក្នុងក្រុង ស្រុកដែលបានជ្រើសរើសចំនួន៤ ថវិកាសម្រាប់ការផ្តល់សេវាត្រូវបានបោះផ្សាយក្នុងទម្រង់ដែលងាយស្រួលយល់សម្រាប់ប្រជាពលរដ្ឋ"។ ការអង្កេតនេះបានរកឃើញភស្តុតាងពីភាពខ្វះចន្លោះ ដែលប្រជាពលរដ្ឋ បុគ្គលិកអង្គការសង្គមស៊ីវិល និងបុគ្គលិករដ្ឋបាលក្រុង ស្រុក និងក្រុមប្រឹក្សាបានយល់ដឹង ប្រើប្រាស់ និងយល់ឃើញអំពីថវិកាក្រុង ស្រុក។ ការរកឃើញទាំងនេះ ក៏កំណត់នូវឱកាសដើម្បីកសាងសមត្ថភាពរដ្ឋបាលក្រុង ស្រុក កែលម្អការផ្សព្វផ្សាយព័ត៌មានថវិកា និងជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ។

## 2. វិធីសាស្ត្រស្រាវជ្រាវ

### 2.1. ដំណាក់កាលក្នុងការស្រាវជ្រាវ

- **ការស្រាវជ្រាវទុតិយ រួមមានការត្រួតពិនិត្យមើលឯកសារដែលមានស្រាប់ឡើងវិញ៖** i) ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានផ្លូវការនានា រួមទាំងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ii) ប្រភពឯកសារផ្លូវការរបស់រាជរដ្ឋាភិបាល៖ ប្រព័ន្ធទិន្នន័យឃុំ សង្កាត់ អនឡាញ(CDB)[4] និងប្រព័ន្ធទិន្នន័យអនុវត្តគម្រោង (PID)[5] iii) ប្រភពឯកសាររបស់អង្គការមិនមែនរដ្ឋាភិបាល៖ របាយការណ៍អង្កេតស្តីពីថវិកាបើកទូលាយ (OBS) សន្ទស្សន៍ថវិកាបើកទូលាយ និងរបាយការណ៍ឆ្នាំ២០១៨ ស្តីពីគណនេយ្យភាព និងតម្លាភាពក្នុងដំណើរការរៀបចំថវិកា ដែលចេញផ្សាយដោយអង្គការតម្លាភាពអន្តរជាតិ។
- **ការស្រាវជ្រាវបឋម៖** ជាការប្រមូលទិន្នន័យដោយផ្ទាល់ទាំងពីនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានជួបសម្ភាសន៍ជាមួយគ្រប់ភាគីដែលស្ថិតក្នុងវិស័យពាក់ព័ន្ធ។ ការអង្កេតនេះបានប្រើវិធីសាស្ត្រពីររួមគ្នា ក្នុងទម្រង់ជាទិន្នន័យបែបបរិមាណ និងបែបគុណភាព ដោយបានប្រមូលពី ៤ក្រុមផ្សេងគ្នា រួមមាន i) ការជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋនៅក្នុងក្រុង ស្រុកដែលបានជ្រើសរើសទាំង១១ ii) ការជួបសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះនៅថ្នាក់ក្រោមជាតិ ក្នុងនោះមានតំណាងក្រុង ស្រុក និងអង្គការសង្គមស៊ីវិលនៅក្នុងក្រុង ស្រុកដែលបានជ្រើសរើស

---

[4] គ.ជ.អ.ប "ប្រព័ន្ធទិន្នន័យឃុំ" ចូលទៅយកទិន្នន័យនៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦, http://db.ncdd.gov.kh/cdbonline/home/index.castle

[5] គ.ជ.អ.ប "ប្រព័ន្ធទិន្នន័យអនុវត្តគម្រោង" ចូលទៅយកទិន្នន័យនៅថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០១៦, http://db.ncdd.gov.kh/pid/project/home/index.castle

ទាំង ១១ iii) ការពិភាក្សាក្រុមគោលដៅជាមួយប្រជាពលរដ្ឋ មន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក និងអង្គការសង្គមស៊ីវិលនៅក្នុងក្រុង ស្រុកដែលបានជ្រើសរើសទាំង ១១ និង iv) ការជួបសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះនៅថ្នាក់ជាតិ ក្នុងនោះមានមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងអង្គការសង្គមស៊ីវិលនៅរាជធានីភ្នំពេញ។

## 2.2. យុទ្ធសាស្ត្រជ្រើសរើសសំណាក និងប្រមូលទិន្នន័យ

ការអង្កេត និងកម្រងសំណួរត្រូវបានរៀបចំឡើងតាមវិធីសាស្ត្របែបចំណេះដឹង ឥរិយាបថ និងការអនុវត្ត (KAP) ក្នុងគោលបំណង i) វាយតម្លៃការយល់ដឹង ការប្រើប្រាស់ និងការយល់ឃើញរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល មន្ត្រីរដ្ឋបាលក្រុង ស្រុក និងក្រុមប្រឹក្សាក្រុង ស្រុក ចំពោះថវិកាក្រុង ស្រុករបស់ខ្លួន ii) កំណត់រកឱ្យឃើញពីសម្ភារៈ ឬឯកសារផ្សព្វផ្សាយ ប្រធានបទបណ្ដុះបណ្ដាល និងយុទ្ធសាស្ត្រផ្សព្វផ្សាយថ្មីៗចំពោះថវិកាក្រុង ស្រុក និងiii) ស្វែងយល់ពីចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋក្នុងការចូលរួមលើកិច្ចការថវិការបស់ក្រុង ស្រុក។

ការអង្កេតនេះត្រូវបានធ្វើឡើងនៅក្នុងក្រុង ស្រុកនៃខេត្តបាត់ដំបង ដែលជាខេត្តគោលដៅក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងនៅក្នុងក្រុង ស្រុក ពីរផ្សេងទៀតនៃខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន ដែលស្ថិតនៅក្បែរខេត្តគោលដៅរបស់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការប្រមូលទិន្នន័យត្រូវបានធ្វើឡើងក្នុងក្រុង ស្រុក សរុបចំនួន ១១ ក្នុងនោះមាន ៧ក្រុង ស្រុក ក្នុងខេត្តបាត់ដំបង ២ក្រុង ស្រុក ក្នុងខេត្តពោធិ៍សាត់ និង ២ ក្រុង ស្រុក ទៀតក្នុងខេត្តប៉ៃលិន។

ការប្រមូលទិន្នន័យនៅថ្នាក់ក្រុង ស្រុកត្រូវបានធ្វើឡើងនៅចន្លោះថ្ងៃទី១៧ ខែកុម្ភៈ ដល់ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ហើយកិច្ចសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះនៅថ្នាក់ជាតិត្រូវបានធ្វើឡើងនៅភ្នំពេញ រវាងសប្ដាហ៍ទី១ និងសប្ដាហ៍ទី២ នៃខែមីនា ឆ្នាំ២០២០។

*រូបភាព ២.១៖ ក្រុង ស្រុកគោលដៅ*




## 2.2.1. ការស្ទង់មតិប្រជាពលរដ្ឋ

គោលបំណងនៃការធ្វើអង្កេតប្រជាពលរដ្ឋ គឺដើម្បី ១)វាយតម្លៃអំពីរបៀបទទួលបាន ប្រើប្រាស់ និងយល់ដឹងជាសាធារណៈអំពីថវិកាក្រុង ស្រុក ២) ស្វែងយល់ពីការចូលរួម និងចំណាប់អារម្មណ៍របស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំផែនការថវិកា និង ៣)សិក្សាពីសក្តានុពលដើម្បីរៀបចំបង្កើតសម្ភារៈ ឬឯកសារ និងយុទ្ធសាស្ត្រ ដែលអាចផ្តល់ប្រសិទ្ធភាពខ្ពស់ក្នុងការផ្សព្វផ្សាយជាសាធារណៈពីថវិកាក្រុង ស្រុក។ ការអង្កេតនេះ ត្រូវបានធ្វើជាមួយប្រជាពលរដ្ឋក្នុងក្រុង ស្រុកចំនួន១១ ដែលក្នុងមួយក្រុង ស្រុក មានចំនួន ៣០ នាក់ សរុបប្រជាពលរដ្ឋចំនួន ៣៣០ នាក់។ ប៉ុន្តែ ដោយសារដើម្បីបញ្ចៀសការបាត់ចំនួនប្រជាពលរដ្ឋនៅក្នុងការអង្កេតនេះ ហើយក្រុមការងារប្រមូលទិន្នន័យធ្វើការអង្កេតនៅតំបន់ផ្សេងៗគ្នាក្នុងពេលតែមួយ ហេតុនេះចំនួនប្រជាពលរដ្ឋធ្វើការអង្កេតសរុបមានចំនួនដល់ទៅ ៣៤០ នាក់។

ការជ្រើសរើសអ្នកចូលរួមក្នុងការអង្កេត ត្រូវបានធ្វើឡើងតាម២ដំណាក់កាល។ ទី១ ការជ្រើសរើសតាមរយៈការកំណត់ឃុំ/សង្កាត់ដែលនឹងត្រូវធ្វើការអង្កេត។ ដោយសន្មតថា ចម្ងាយរវាងលំនៅដ្ឋានរបស់ប្រជាជនទៅកាន់សាលាក្រុង ស្រុក អាចជះឥទ្ធិពលលើការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការ

ទទួលបានព័ត៌មានសាធារណៈ ហេតុនេះទើបឃុំ/សង្កាត់ត្រូវបានញែកចេញជាបីប្រភេទ (ឃុំដែលស្ថិតនៅឆ្ងាយ មធ្យម និងជិត) ដោយផ្អែកទៅតាមចម្ងាយជាមធ្យមទៅកាន់សាលាក្រុង ស្រុក។ បន្ទាប់មកឃុំ/សង្កាត់ចំនួនមួយក្នុងចំណោមឃុំ/សង្កាត់ទាំងអស់ត្រូវបានជ្រើសរើសដោយចៃដន្យ ដើម្បីធ្វើការអង្កេតប្រជាពលរដ្ឋ (សូមមើលផែនទីក្នុងឧបសម្ព័ន្ធទី ១ សម្រាប់ព័ត៌មានលម្អិតបន្ថែម)។

ដំណាក់កាលទី ២ គឺការរៀបចំសំណាកដើម្បីគ្របដណ្តប់អ្នកចូលរួមក្នុងការអង្កេត ដោយផ្តោតលើយេនឌ័រ ស្ថានភាពសេដ្ឋកិច្ច សង្គម និងកម្រិតនៃការអប់រំ។ ដោយសារចំនួនប្រជាពលរដ្ឋនៅក្នុងការអង្កេតនេះមានចំនួនតិច ហេតុនេះចំនួនសំណាកខាងលើមិនបានតំណាងឱ្យចំនួនប្រជាពលរដ្ឋសរុបដែលមាននៅក្នុងក្រុង ស្រុកទាំងអស់នោះទេ។ ផ្ទុយទៅវិញ ចំនួនសំណាកខាងលើនេះមានគោលបំណងស្វែងយល់ពីការយល់ឃើញរបស់ប្រជាពលរដ្ឋដែលមានសមាសភាពចម្រុះ ដើម្បីកំណត់យុទ្ធសាស្ត្រ និងរៀបចំបង្កើតសម្ភារៈ ឬឯកសារ ដែលអាចផ្តល់ប្រសិទ្ធភាពខ្ពស់ក្នុងការផ្សព្វផ្សាយជាសាធារណៈពីថវិកាក្រុង ស្រុក។

ការអង្កេតប្រជាពលរដ្ឋនេះត្រូវបានធ្វើឡើងដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ចំនួន៦នាក់ ដែលធ្លាប់ឬបានកំពុងធ្វើការជាមួយអង្គការដែលអនុវត្តផែនការអនុវត្តសម្រាប់គណនេយ្យសង្គម (I-SAF) ក្រោមការណែនាំពីក្រុមការងារអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី)។ ក្រុមខាងលើនេះបានទទួលការបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃ ទៅលើកម្រងសំណួរសម្រាប់ការអង្កេត និងការប្រើប្រាស់ KoBo Toolbox[6] ដែលជាឧបករណ៍សម្រាប់ប្រមូលទិន្នន័យ ពីអង្គការអូឌីស៊ីមុននឹងចុះប្រមូលទិន្នន័យនៅតាមក្រុង ស្រុក។ KoBo Toolbox គឺជាកម្មវិធីមួយដែលត្រូវបានគេប្រើប្រាស់ជាទូទៅសម្រាប់ការចុះប្រមូលទិន្នន័យក្នុងការស្រាវជ្រាវ ដែលវាអាចរក្សាទិន្នន័យបានដោយស្វ័យប្រវត្តិ។ ឧបករណ៍នេះអាចជួយបញ្ចៀសហានិភ័យក្នុងការបាត់បង់ទិន្នន័យបាន ក្នុងករណីមិនមានការតភ្ជាប់អ៊ីនធើណេតក្នុងតំបន់ដាច់ស្រយាល ដោយសារវាអាចប្រើបានទាំងអនឡាញ និងមិនអនឡាញ។

### 2.2.2. កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ (KII)

ក្រុមការងាររបស់អង្គការអូឌីស៊ី និងទីប្រឹក្សាខាងក្រៅចំនួនពីររូប បានធ្វើបទសម្ភាសន៍បែបស៊ីជម្រៅជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះដោយផ្ទាល់ ទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។

[6] ព័ត៌មានលម្អិតបន្ថែមអំពី KoBo Toolbox អាចរកបាននៅលើគេហទំព័រផ្លូវការ https://www.kobotoolbox.org

## កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះនៅរដ្ឋបាលក្រុង ស្រុក និងអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ

ក្រុមការងារបានធ្វើបទសម្ភាសន៍ដោយផ្ទាល់ជាមួយក្រុមប្រឹក្សាក្រុង ស្រុក បុគ្គលិករដ្ឋបាលក្រុង ស្រុក តំណាងអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធក្នុងផែនការអនុវត្តសម្រាប់គណនេយ្យសង្គម (I-SAF) ចំនួន ៦៩ រូប ដែលជាអ្នកមានតួនាទី និងភារកិច្ច ឬធ្វើការងារពាក់ព័ន្ធលើការជំរុញការផ្សព្វផ្សាយ ឬការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំថវិកាសាធារណៈនៅថ្នាក់ក្រោមជាតិ។ នៅថ្នាក់ក្រុង ស្រុក កិច្ចសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះត្រូវបានធ្វើជាមួយប្រធានក្រុមប្រឹក្សា សមាជិកនៃគណៈកម្មាធិការលទ្ធកម្ម សមាជិកនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សមាជិកនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងអភិបាលរងទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុក្រុង ស្រុក។ នៅថ្នាក់ខេត្ត ការសម្ភាសន៍ត្រូវបានធ្វើជាមួយប្រធានសមាគមក្រុមប្រឹក្សាខេត្ត និងជនបង្គោលសម្របសម្រួលការងារគណនេយ្យភាពសង្គម I-SAF ប្រចាំខេត្ត មួយរូប។

ទន្ទឹមនឹងនេះ កិច្ចសម្ភាសន៍ក៏ត្រូវបានធ្វើជាមួយអង្គការសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិផងដែរ ក្នុងមានអង្គការចំនួន ៤ គឺសមាគមអភិវឌ្ឍជនបទ (RDA) អង្គការក្រុមទ្រទ្រង់ភូមិ (VSG) អង្គការវឌ្ឍនភាព (WP) និងអង្គការទស្សនៈពិភពលោក។ អង្គការទស្សនៈពិភពលោក គឺកំពុងអនុវត្ត I-SAF ក្នុងខេត្តបាត់ដំបង ខណៈដែលអង្គការដទៃទៀតត្រូវបានជ្រើសរើសដោយផ្អែកលើសកម្មភាពដែលពួកគេកំពុងធ្វើការងារជាមួយនឹងសហគមន៍មូលដ្ឋានពាក់ព័ន្ធនឹងការផ្តល់សេវា គណនេយ្យភាពសង្គម និងការចូលរួមរបស់ប្រជាពលរដ្ឋ។ ដោយឡែក អ្នកសម្របសម្រួលការងារគណនេយ្យភាពសង្គមសហគមន៍ (CAF) នៅថ្នាក់ឃុំ ចំនួន ២រូប ក៏ត្រូវបានការធ្វើកិច្ចសម្ភាសន៍ផងដែរ ក្នុងនាមជាតំណាងផ្នែកទទួលសេវារបស់ I-SAF។

## កិច្ចសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះដែលជាមន្ត្រីរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ

កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយក្រសួង ស្ថាប័នចំនួន ៤ ក្នុងនោះមាន លេខាធិការដ្ឋាន គ.ជ.អ.ប នាយកដ្ឋានកិច្ចការរដ្ឋបាល ក្រុង ស្រុក ឃុំ សង្កាត់នៃក្រសួងមហាផ្ទៃ នាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (NLC)។ ចំណែក អង្គការសង្គមស៊ីវិលដែលបានសម្ភាសន៍នៅរាជធានីភ្នំពេញ

រួមមាន ១) អង្គការយៃរ ២) អង្គការអុកស្វាម ៣) អង្គការវ៉ាឆា ៤) អង្គការស្ដារកម្ពុជា និង ៥) អង្គការតម្លាភាពអន្តរជាតិ។

### 2.2.3. ការពិភាក្សាជាមួយក្រុមគោលដៅ (FGD)

កិច្ចសម្ភាសន៍ត្រូវបានធ្វើឡើងជាលក្ខណៈក្រុមតូចៗ ក្នុងគោលបំណងដើម្បីប្រមូលមតិយោបល់ ឬ ទស្សនៈនានាពីក្រុមមនុស្សផ្សេងៗគ្នា ដែលវាមានលក្ខណៈងាយស្រួលក្នុងការបត់បែនជាងកិច្ចសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ (KII)។ ការពិភាក្សានេះត្រូវបានផ្ដោតជាពិសេសទៅលើប្រធានបទការអភិវឌ្ឍសមត្ថភាព ការផ្សព្វផ្សាយឯកសារអប់រំ និងទម្រង់ថវិកាគំរូដែលអាចងាយយល់សម្រាប់ប្រជាពលរដ្ឋ។ ការពិភាក្សាជាមួយក្រុមគោលដៅ (FGD)នេះត្រូវបានរៀបចំនៅតាមក្រុង ស្រុកទាំង១១ ដែលមានចំនួនសរុប ១១លើក ដោយមានការសម្របសម្រួលពីក្រុមការងាររបស់អង្គការអូឌីស៊ី។ ទោះបីជាយើងមានបំណងប្រមូលបុគ្គលិករដ្ឋបាលក្រុង ស្រុក អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ ឱ្យចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅនេះយ៉ាងណាក៏ដោយ ក៏យើងមានការលំបាកក្នុងការរាប់ចំនួនអ្នកចូលរួមនៃក្រុមពីរចុងក្រោយ ដោយសារពេលវេលាខ្លីពេក។

### 2.2.4. សិក្ខាសាលាពិគ្រោះយោបល់

សិក្ខាសាលាពិគ្រោះយោបល់ចំនួន ២លើក ត្រូវបានរៀបចំឡើងនៅក្នុងខេត្តបាត់ដំបង និងរាជធានីភ្នំពេញ ក្នុងគោលបំណងដើម្បីពិនិត្យផ្ទៀងផ្ទាត់ទៅលើលទ្ធផលនៃការអង្កេតនេះ។ លទ្ធផលនៃការរកឃើញ និងអនុសាសន៍នានាត្រូវបានបង្ហាញដល់មន្ត្រីរដ្ឋបាលក្រុង ស្រុក និងក្រសួង ស្ថាប័នថ្នាក់ជាតិ។ ការពិភាក្សាដេញដោល និងកិច្ចពិភាក្សាជាក្រុមត្រូវបានធ្វើឡើងយ៉ាងផុសផុលទៅលើលទ្ធផលនៃការអង្កេត ហើយអ្នកចូលរួមបានផ្ដល់អនុសាសន៍នានាដែលមានលក្ខណៈសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុកយកទៅអនុវត្ត។ ជាទូទៅ ការអង្កេតនេះមានការជ្រួតជ្រាបបានល្អ ពីព្រោះអ្នកចូលរួមបានសង្កត់ធ្ងន់លើការយល់ដឹងមានកម្រិតទៅលើគណនេយ្យភាពរបស់អាជ្ញាធរមូលដ្ឋាន និងតម្រូវការក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃការចូលរួមរបស់រដ្ឋបាលក្រុង ស្រុកក្នុងគម្រោងផ្សេងៗ ដែលសំដៅបង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ។

អ្នកចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ រួមមានអ្នកពាក់ព័ន្ធដែលភាគច្រើនធ្លាប់បានចូលរួមក្នុងការពិគ្រោះយោបល់ និងសម្ភាសន៍កន្លងមកដូចជាតំណាងមកពីរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រុង ស្រុក ក៏ដូចជាសមាជិកអង្គការសង្គមស៊ីវិល។

- អ្នកចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ក្នុងខេត្តបាត់ដំបង៖ រដ្ឋបាលក្រុង ស្រុកមកពីបាណន់ ក្រុងបាត់ដំបង បវិល កំរៀង មោងឫស្សី រតនមណ្ឌល ថ្មគោល និងអង្គការសង្គមស៊ីវិលដូចជា អង្គការជីវិតថ្លៃថ្នូរ និងអង្គការក្រុមទ្រទ្រង់ភូមិ។

- អ្នកចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់នៅភ្នំពេញ៖ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) អង្គការក្រុមការងារដោះស្រាយទំនាស់ (ACT) អង្គការភាពជាដៃគូសង្គមស៊ីវិលកម្ពុជា (CCSP) លេខាធិការដ្ឋានរួមនៃសមាគមន៍ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ (ASAC-S) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) លេខាធិការដ្ឋាន គ.ជ.អ.ប (NCDD-S) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGOF) សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ (RACHA) អង្គការតម្លាភាពអន្តរជាតិ (TI) ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)។

# 3. លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ

## 3.1. លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ

ការអង្កេតនេះត្រូវបានរៀបចំមានលក្ខណៈចម្រុះលក្ខណៈវិនិច្ឆ័យ ក្នុងនោះមានអាយុ យេនឌ័រ កម្រិតអប់រំ និងមុខរបរ។ ការអង្កេតនេះមានសំណាកសរុបចំនួន ៣៤០នាក់ ក្នុងនោះមានបុរសចំនួន ១៤៧ នាក់ និងស្ត្រីចំនួន ១៩៣ នាក់ ដែលជាមនុស្សពេញវ័យ និងទៅតាមក្រុមអាយុផ្សេងៗគ្នា។

*រូបភាព ៣.១៖ ប្រជាពលរដ្ឋដែលបានផ្តល់សម្ភាសន៍នៅតាមបណ្តាខេត្ត និងយេនឌ័រ*

| **១៣០** | **ខេត្តបាត់ដំបង** | **៨៧** |
|---|---|---|
| ១៥ | ស្រុកបាណន់ | ១៦ |
| ២៤ | ក្រុងបាត់ដំបង | ១១ |
| ១៧ | ស្រុកបវិល | ១៥ |
| ១៦ | ស្រុកកំរៀង | ១៣ |
| ២៣ | ស្រុកមោងឫស្សី | ៧ |
| ១៨ | ស្រុករតនៈមណ្ឌល | ១២ |
| ១៧ | ស្រុកថ្មគោល | ១៣ |
| **២៨** | **ខេត្តប៉ៃលិន** | **៣២** |
| ១៥ | ក្រុងប៉ៃលិន | ១៦ |
| ១៣ | ស្រុកសាលាក្រៅ | ១៦ |
| **៣៥** | **ខេត្តពោធិ៍សាត់** | **២៨** |
| ១៦ | ស្រុកបាកាន | ១៣ |
| ១៩ | ក្រុងពោធិ៍សាត់ | ១៥ |

តាមរយៈការអង្កេតនេះ សំណាកជាស្ត្រីមានច្រើនជាងបុរស ដោយសារស្ត្រីងាយជួបជាង។ ពួកគាត់លក់ដូរ និងប្រកបអាជីវកម្មតូចៗនៅតាមទីប្រជុំជន និងតាមដងផ្លូវ ហើយពួកគាត់នៅផ្ទះមើលថែកូនចៅ ខណៈដែលបុរសវិញរវល់ធ្វើការនៅស្រែឬចំការ។ នៅពេលដែលក្រុមការងារចុះសម្ភាន៍ជួបទាំងបុរស ទាំងស្ត្រីនៅផ្ទះ ស្ត្រីជាធម្មតាមានបំណងចង់ចូលរួមជាងបុរស។

អ្នកផ្តល់សម្ភាសន៍ក្នុងក្រុមអាយុក្មេងបំផុតចន្លោះពី១៨ ដល់ ២៧ ឆ្នាំ គឺមានចំនួនតិចខ្លាំង បើធៀបនឹងក្រុមអាយុចន្លោះពី ២៨ ដល់ ៣៧ ឆ្នាំ និងចន្លោះពី ៤៨ ដល់ ៥៧ ឆ្នាំ ដែលមានចំនួនជិត ៥០%។ ការចុះជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលមានវ័យក្មេងប្រឈមនឹងការលំបាក ដោយសារមូលហេតុ ២យ៉ាងគឺ៖ ទី១ ការចុះជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋភាគច្រើនធ្វើឡើងក្នុងថ្ងៃធ្វើការ ដែលពេលនោះជាពេលដែលប្រជាពលរដ្ឋក្នុងវ័យនេះរវល់បំពេញការងាររបស់ខ្លួន និង ទី២ តំបន់នៅជិតព្រំដែនថៃបង្កភាពងាយស្រួលដល់ប្រជាពលរដ្ឋក្នុងវ័យនេះធ្វើចំណាកស្រុកដើម្បីស្វែងរកអនាគតល្អជាងនេះ។ ក្រៅពីនេះ ផ្ទុយពីអ្នកផ្តល់សម្ភាសន៍ជាស្ត្រី អ្នកផ្តល់សម្ភាសន៍ជាបុរសភាគច្រើនស្ថិតក្នុងក្រុមវ័យរាងចំណាស់ ដែលនេះអាចនិយាយបានថា បុរសដែលមានវ័យកាន់តែចាស់ នោះគាត់មិនសូវទៅធ្វើការនៅស្រែ ឬចំការទេ។

*រូបភាព ៣.២៖ ការបែងចែកចំណាត់ថ្នាក់នៃអ្នកផ្តល់សម្ភាសន៍ទៅតាមក្រុមអាយុ និងយេនឌ័រជាភាគរយធៀបនឹងចំនួនប្រជាពលរដ្ឋដែលបានសម្ភាសន៍សរុប*



ផ្អែកតាមរូបភាព ៣.៣ អ្នកផ្តល់សម្ភាសន៍បានបង្ហាញលក្ខណៈដូចៗគ្នាពាក់ព័ន្ធនឹងកម្រិតអប់រំ និងមុខរបរ ជាពិសេសអ្នករស់នៅតំបន់ជនបទដាច់ស្រយាលខ្លាំង។ ជាទូទៅ អ្នកផ្តល់សម្ភាសន៍៨ នាក់ ក្នុងចំណោម ១០ នាក់ មានមុខរបរជា កសិករ មេផ្ទះ និងអ្នកលក់ដូរ។

ទោះបីជាយេនឌ័រមិនទំនងជាកត្តាកំណត់ថាស្ត្រីត្រូវតែមានកម្រិតអប់រំទាបជាងបុរសយ៉ាងណាក៏ដោយ ប៉ុន្តែអ្នកដែលមានការអប់រំខ្ពស់ភាគច្រើនគឺជាបុរស។ ភាគរយប្រជាពលរដ្ឋដែលមានការអប់រំនៅត្រឹមកម្រិតបឋមសិក្សា គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាចំពោះស្ត្រីនិងបុរស។ ដោយឡែក អ្នកផ្តល់សម្ភាសន៍ជាបុរសដែលមានការអប់រំត្រឹមកម្រិតមធ្យមសិក្សា មានចំនួន១២% បើធៀបនឹងស្ត្រីមានត្រឹមតែ ៧% ប៉ុណ្ណោះ។ ក្រៅពីនេះ ស្ត្រីដែលមិនធ្លាប់បានទទួលការអប់រំក្រៅប្រព័ន្ធមានភាគរយ (២០%) ច្រើនជាងបុរស (១៦%)។ អ្នកផ្តល់សម្ភាសន៍ជាបុរសជិត៥០% គឺជាកម្មករបម្រើការងារក្នុងវិស័យសេដ្ឋកិច្ចចម្បង ដូចជាកសិកម្ម នេសាទ និងការដាំដុះ ហើយមាន២០% ជាអ្នកលក់ដូរ និង១០% ទៀតជាអ្នកគ្មានការងារធ្វើ។ ក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ជាស្ត្រី មាន៤១% ជាមេផ្ទះ ២៥% ជាកម្មករបម្រើការងារក្នុងវិស័យសេដ្ឋកិច្ចចម្បង និង ២៥% ទៀតជាអ្នកលក់ដូរ។

ដោយសារតែសំណាកចំពោះអ្នកផ្តល់សម្ភាសន៍ស្ថិតក្នុងអាជីពតែមួយដូចគ្នា បង្កឱ្យការអង្កេតមិនអាចវិភាគបានច្រើនជាងនេះ។ កត្តានេះបង្កមកពីការអង្កេតធ្វើឡើងតែក្នុងអំឡុងម៉ោងធ្វើការ ដែលក្រុមការងារអាចជួបសម្ភាសន៍បានតែអ្នកនៅផ្ទះ អ្នកធ្វើការងារក្នុងវិស័យកសិកម្ម និងអ្នកបម្រើការងារនៅតាមហាងប៉ុណ្ណោះ។ ចំណែក អ្នកបម្រើការងារក្នុងការិយាល័យ ដូចជាវិស័យធនាគារ មីក្រូហិរញ្ញវត្ថុ ទូរគមនាគមន៍ និងក្រុមហ៊ុនឯកជន ដែលភាគច្រើនជាអ្នកមានការអប់រំខ្ពស់ ក្រុមការងារមិនបានជួបសម្ភាសន៍នោះទេ ដែលជាហេតុធ្វើឱ្យខ្វះសំណាកពីក្រុមដែលស្ថិតក្នុងអាជីពនេះ។

*រូបភាព ៣.៣៖ កម្រិតអប់រំ និងមុខរបររបស់ប្រជាពលរដ្ឋដែលបានផ្ដល់សម្ភាសន៍ទៅតាមយេនឌ័រ*

**កម្រិតនៃការអប់រំរបស់ស្ត្រី**




1 សាកលវិទ្យាល័យ 2 ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ

Created with Datawrapper

**មុខរបររបស់ស្ត្រី**

វិស័យសេដ្ឋកិច្ចចម្បងសំដៅទៅលើវិស័យកសិកម្ម នេសាទ និងការដាំដុះ។ មុខរបរក្រៅពីនេះ រួមមានមន្ត្រីរាជការ កម្មករសំណង់និងរោងចក្រ ពលករ លក់ដូរ កម្មករក្នុងវិស័យសេវាកម្ម និងអ្នកគ្មានការងារធ្វើ។




Created with Datawrapper

**កម្រិតនៃការអប់រំរបស់បុរស**




1 សាកលវិទ្យាល័យ

Created with Datawrapper

**មុខរបររបស់បុរស**

វិស័យសេដ្ឋកិច្ចចម្បងសំដៅទៅលើវិស័យកសិកម្ម នេសាទ និងការដាំដុះ។ មុខរបរក្រៅពីនេះ រួមមានមន្ត្រីរាជការ កម្មករសំណង់ ពលករ លក់ដូរ និងកម្មករក្នុងវិស័យសេវាកម្ម ។




Created with Datawrapper

## 3.2 កិច្ចសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះនៅរដ្ឋបាលក្រុង ស្រុក

កិច្ចសម្ភាសន៍ជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះមានចំនួនសរុប ៦៩ នាក់នៅថ្នាក់ក្រុង ស្រុក។ អ្នកផ្ដល់សម្ភាសន៍ជាបុរសមានចំនួនច្រើនជាងស្ត្រី ដែលក្នុងនោះមានស្ត្រី ២៣នាក់ និង បុរស៤៦នាក់។ រូបភាព ៣.៤ បង្ហាញពីចំនួនអ្នកផ្ដល់សម្ភាសន៍ក្នុងការអង្កេតតាមមុខតំណែងនីមួយៗនិងតាមយេនឌ័រ។ ស្ត្រី

ជារឿយៗត្រូវបានគេតែងតាំងក្នុងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ខណៈដែលតំណែងផ្សេងទៀតភាគច្រើនកាន់ដោយបុរស។

*រូបភាព ៣.៤៖ តំណែងរបស់អ្នកផ្ដល់ព័ត៌មានគន្លឹះនៅថ្នាក់ក្រុង ស្រុកបែងចែកទៅតាមយេនឌ័រ*




សម្គាល់៖ គ.ក.ស.ក គឺគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

ចំពោះកម្រិតអប់រំវិញ ជាទូទៅបុរសមានការអប់រំខ្ពស់ជាងស្ត្រី។ ដូចបានឃើញនៅក្នុងរូបភាព ៣.៥ គឺមានតែ ៧ នាក់ប៉ុណ្ណោះក្នុងចំណោមស្ត្រី ២៣ នាក់ដែលបានសម្ភាសន៍ បានចូលរៀននៅសាកលវិទ្យាល័យ ដែលស្មើនឹង ៣០% នៃស្ត្រីបានចូលរួមក្នុងការសម្ភាសន៍ បើធៀបទៅនឹង ៥០% នៃបុរសចូលរួមក្នុងការសម្ភាសន៍។

*រូបភាព ៣.៥៖ កម្រិតនៃការអប់រំរបស់អ្នកផ្ដល់ព័ត៌មានគន្លឹះនៅថ្នាក់ក្រុង ស្រុកទៅតាមយេនឌ័រ*

| កម្រិតនៃការអប់រំ | បាត់ដំបង | | ប៉ៃលិន | | ពោធិ៍សាត់ | | សរុបតាមកម្រិតអប់រំ | |
|---|---|---|---|---|---|---|---|---|
| | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស | ស្ត្រី | បុរស |
| បឋមសិក្សា | 0 | 3 | 1 | 2 | 0 | 0 | **1** | **5** |
| មធ្យមសិក្សា | 5 | 6 | 1 | 3 | 2 | 0 | **8** | **9** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| វិទ្យាល័យ | 5 | 6 | 0 | 0 | 1 | 2 | **6** | **8** |
| សាកលវិទ្យាល័យ | 3 | 18 | 2 | 4 | 2 | 1 | **7** | **23** |
| សាលាបណ្ដុះបណ្ដាលវិជ្ជាជីវៈ | 0 | 1 | 0 | 0 | 1 | 0 | **1** | **1** |
| សរុបទៅតាមខេត្ត | **13** | **34** | **4** | **9** | **6** | **3** | **23** | **46** |

## 4. ការរកឃើញអំពីចំណេះដឹង ឥរិយាបថ និងការអនុវត្តជាក់ស្ដែងចំពោះថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក

ផ្នែកនេះបង្ហាញពីការវាយតម្លៃចំពោះរបៀបដែលប្រជាពលរដ្ឋនិងក្រុមមនុស្សផ្សេងទៀតមានការយល់ដឹង មានការយល់ឃើញ និងប្រើប្រាស់អំពីព័ត៌មានថវិកា។

### 4.1. ចំណេះដឹង ឥរិយាបថ និងការអនុវត្តជាក់ស្ដែងរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋបានបង្ហាញថា មានការខ្វះខាតចំណេះដឹងអំពីថវិការបស់រដ្ឋបាលក្រុង ស្រុកខ្លួនមករហូត។ តាមពិត មានតែអ្នកចូលរួមចំនួន ២ នាក់ប៉ុណ្ណោះក្នុងចំណោម ៣៤០ នាក់ដែលអាចប្រាប់អំពីចំនួនថវិកាក្រុង ស្រុកនៅឆ្នាំកន្លងទៅ។ ដូចគ្នានេះដែរ ប្រជាពលរដ្ឋកម្រមានលទ្ធភាពដឹងអំពីថវិកា ឬឯកសារដែលមានព័ត៌មានថវិកាណាស់។

ភាគច្រើននៃប្រជាពលរដ្ឋមិនបានដឹងថា តើថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុកខ្លួនមានផ្សព្វផ្សាយជាសាធារណៈឡើយ ក្នុងនោះមានពលរដ្ឋ ៧៧% ក្នុងខេត្តបាត់ដំបង ៨៧% ក្នុងខេត្តប៉ៃលិន និង៧០% ក្នុងខេត្តពោធិ៍សាត់ពុំបានដឹង។ ការអង្កេតបង្ហាញថា ស្ត្រីមិនបានយល់ដឹងពីព័ត៌មានថវិកាមានកម្រិតភាគរយចន្លោះពី ៣% ទៅ ៥% ច្រើនជាងបុរស នៅក្នុងខេត្តទាំង ៣។

ទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋស្ដីពីសារៈសំខាន់នៃព័ត៌មានថវិកាមានភាពខុសៗគ្នា។ ជាទូទៅ ប្រជាពលរដ្ឋដែលចូលរួមក្នុងការអង្កេតតែ ១៥% ប៉ុណ្ណោះដែលបានប្រាប់ថា ព័ត៌មានពាក់ព័ន្ធនឹងថវិកាមានសារៈសំខាន់ណាស់ចំពោះពួកគាត់។ ប្រជាពលរដ្ឋ៤៧% គិតថាព័ត៌មានថវិកាមានសារៈសំខាន់ខ្លះដែរ ហើយ ៣៨% ទៀតប្រាប់ថាមិនសំខាន់។

*រូបភាព ៤.១៖ ទស្សនៈយល់ឃើញរបស់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃព័ត៌មានថវិកាក្រុង ស្រុក*




មូលហេតុចម្បងដែលប្រជាពលរដ្ឋដែលមានទស្សនៈយល់ឃើញថា ព័ត៌មានថវិកា *មានសារៈសំខាន់* ឬ *មានសារៈសំខាន់ខ្លះដែរ* គឺ៖ i) មានប្រយោជន៍សម្រាប់ខ្លួនឯង ii) ព័ត៌មានគឺពាក់ព័ន្ធនឹងការងាររបស់ពួកគាត់ និង iii) ថវិកាមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសហគមន៍របស់ខ្លួន។

ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ខ្លាំងក្នុងការចង់ដឹងបន្ថែមអំពីថវិកាក្រុង ស្រុក។ ៦៥% នៃអ្នកផ្តល់សម្ភាសន៍ចង់ដឹងបន្ថែមអំពីការវិភាជន៍ថវិកាប្រចាំឆ្នាំក្រុង ស្រុក។ ចំណុចនេះ គួរជាការលើកទឹកចិត្តចំពោះរដ្ឋបាលដើម្បីជំរុញការផ្សព្វផ្សាយពីព័ត៌មាននេះឱ្យបានកាន់តែច្រើនបន្ថែមទៀត។ ប៉ុន្តែទោះមានការបង្ហាញអំពីចំណាប់អារម្មណ៍យ៉ាងនេះក្តី ក៏ប្រជាពលរដ្ឋកម្រចាត់វិធានការដើម្បីស្វែងរកព័ត៌មាននេះដោយខ្លួនឯងណាស់។

មានតែអ្នកផ្តល់សម្ភាសន៍ ២ នាក់ប៉ុណ្ណោះដែលបានរាយការណ៍ថា ធ្លាប់បានស្នើសុំព័ត៌មានអំពីថវិកាក្រុង ស្រុកពីអាជ្ញាធរមូលដ្ឋាន។ ជាទូទៅ ៤៨% នៃអ្នកផ្តល់សម្ភាសន៍ធ្លាប់អញ្ជើញទៅសាលាក្រុង ស្រុករបស់ពួកគាត់យ៉ាងហោចណាស់ម្តងក្នុងមួយជីវិតរបស់ពួកគាត់។ តួលេខនេះមានសភាពទាបបន្តិចចំពោះស្ត្រី (៤៥%) ជាងបុរស (៥២%)។ ប្រសិនបើយើងបែងចែកតាមខេត្ត អ្នកផ្តល់សម្ភាសន៍មកពីខេត្តបាត់ដំបងទំនងជាបានអញ្ជើញទៅសាលាក្រុង ស្រុករបស់ខ្លួនបានច្រើនជាង (៥៣%) បើប្រៀបធៀបជាមួយខេត្តប៉ៃលិន (៤០%) និងខេត្តពោធិ៍សាត់ (៤០%)។

### 4.2. ចំណេះដឹង ឥរិយាបថ និងការអនុវត្តជាក់ស្ដែងរបស់រដ្ឋបាលក្រុង ស្រុក

អ្នកផ្ដល់សម្ភាសន៍ទាំងអស់ លើកលែងតែ ៥ រូប ធ្លាប់ទទួលបានព័ត៌មានអំពីថវិកាប្រចាំឆ្នាំនៃរដ្ឋបាលក្រុង ស្រុករបស់ខ្លួន យ៉ាងហោចណាស់ក៏ម្ដងក្នុងមួយឆ្នាំ។ ភាគច្រើន (៩៤%) បានរាយការណ៍ថា ថវិកាត្រូវបានគេផ្សព្វផ្សាយនៅក្នុងរដ្ឋបាល និងប្រគល់ជូនគាត់ ជាទូទៅនៅអំឡុងពេលកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា។

នៅពេលស្នើសុំឱ្យពន្យល់អំពីវដ្ដថវិកា មន្ត្រី និងបុគ្គលិកក្រុង ស្រុកដែលចូលរួមការសម្ភាសន៍មកពីខេត្តទាំង ៣ ស្គាល់ក្របខណ្ឌចម្បង និងការទទួលខុសត្រូវក្នុងការរៀបចំថវិកាប្រចាំឆ្នាំ។ ជាមួយនឹងការជូនដំណឹងនៃការបែងចែកប្រចាំឆ្នាំរបស់មូលនិធិក្រុង ស្រុកសម្រាប់រដ្ឋបាលក្រុង ស្រុក ការិយាល័យរដ្ឋបាល/ហិរញ្ញវត្ថុ និងគណៈអភិបាលចាប់ផ្ដើមរៀបចំផែនការថវិកាសម្រាប់ឆ្នាំបន្ទាប់ ដែលជាទូទៅនៅក្នុងរវាងខែមិថុនា និងកក្កដា។ យោងតាមអ្នកផ្ដល់សម្ភាសន៍ដែលធ្លាប់ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីត្រួតពិនិត្យសេចក្ដីព្រាងនៃថវិកាបានមានប្រសាសន៍ថា វាជាឱកាសដ៏សំខាន់មួយក្នុងការបញ្ជាក់ចម្ងល់របស់ពួកគាត់ និងទទួលយោបល់ត្រលប់ពីក្រសួងថ្នាក់ជាតិ។

ទោះបីជាការអនុញ្ញាតឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងដំណើរការរៀបចំថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក ត្រូវបានគេគិតថាមានភាពវិជ្ជមានយ៉ាងណាក៏ដោយ ក៏ជាងពាក់កណ្ដាលនៃអ្នកផ្ដល់សម្ភាសន៍បាននិយាយថា រដ្ឋបាលក្រុង ស្រុករបស់ខ្លួនមិនបានរៀបចំកិច្ចពិគ្រោះយោបល់ជាសាធារណៈស្ដីពីសេចក្ដីព្រាងថវិកាមុនមានការអនុម័តពីក្រុមប្រឹក្សាឡើយ។ ជាធម្មតា មេឃុំ ប្រធានភូមិ និងតំណាងសហគមន៍ គឺជាអ្នកដែលពាំនាំធាតុចូល និងក្ដីបារម្ភរបស់ប្រជាពលរដ្ឋទៅកាន់ក្រុមប្រឹក្សា។

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) បានចូលរួមក្នុងការរៀបចំថវិកាប្រចាំឆ្នាំក្នុងរដ្ឋបាលក្រុង ស្រុកទាំងអស់។ ចំណុចនេះមានភាពសំខាន់ណាស់ ពីព្រោះ គ.ក.ស.ក ដើរតួយ៉ាងសំខាន់ក្នុងការធានាថាសេចក្ដីត្រូវការ និងអត្ថប្រយោជន៍របស់ក្រុមងាយរងគ្រោះបំផុតទាំង ២ គឺស្ត្រី និងកុមារត្រូវបានលើកឡើងក្នុងដំណើរការរៀបចំថវិកា។

សមាជិកម្នាក់របស់ គ.ក.ស.ក នៅស្រុក បាកាន មានប្រសាសន៍ថា ទោះបីជាគាត់មិនអាចតែងតែចូលរួមគ្រប់កិច្ចប្រជុំយ៉ាងណាក៏ដោយ ដោយសារតែមានការងារជាន់គ្នា ក៏ក្រុមប្រឹក្សាចែករំលែកកំណត់ហេតុអង្គប្រជុំដែរ ដូច្នេះគាត់ពុំបានបាត់នូវព័ត៌មានសំខាន់ៗណាឡើយ។ សមាជិក គ.ក.ស.ក ម្នាក់នៅស្រុករតនមណ្ឌល បានសំដែងភាពពុំសប្បាយចិត្តខ្លះ ដោយសារអង្គហេតុដែលថាមានតែ ៥០% នៃផែនការថវិកាដែលបានស្នើឡើងពីគណៈកម្មាធិការត្រូវបានគេដាក់បញ្ចូលទៅក្នុងផែនការ

ថវិកាប្រចាំឆ្នាំចុងក្រោយប៉ុណ្ណោះ។ អភិបាលរងទទួលបន្ទុកហិរញ្ញវត្ថុក្រុង ស្រុកបានពន្យល់ថា ដោយសារតែចំណេះដឹងផ្នែកហិរញ្ញវត្ថុរបស់ គ.ក.ស.ក នៅមានកម្រិត បានធ្វើឱ្យគាត់មិនបានផ្តល់ធាតុចូលនានាទៅលើសេចក្តីព្រាងថវិកាឡើយ រង់ចាំរហូតទាល់តែសេចក្តីព្រាងថវិកាត្រូវបានបុគ្គលិកហិរញ្ញវត្ថុរៀបចំបញ្ចប់រួចរាល់ ទើប គ.ក.ស.ក អាចលើកជាសំណួរ ប្រសិនបើមាន។

ការចំណាយពេលរបស់ក្រុមប្រឹក្សាក្នុងការអនុម័តសេចក្តីព្រាងថវិកា មិនបានកំណត់ច្បាស់លាស់ឡើយ ហើយតម្រូវឱ្យមានកិច្ចប្រជុំបន្ទាន់ៗជាច្រើនលើកច្រើនសារនៅពេលពុំមានការយល់ស្របគ្នាក្នុងចំណោមក្រុមប្រឹក្សា ឬនៅពេលថវិកាមិនមានភាពច្បាស់លាស់។ នៅពេលដែលសេចក្តីព្រាងថវិកាទទួលបានការអនុម័តរួច ក្រុមប្រឹក្សាជាអ្នកទទួលបន្ទុកដាក់ឯកសារនេះទៅកាន់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ការពន្យាម្តងម្កាលក្នុងការជូនដំណឹងអំពីការវិភាជន៍ថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុកដល់រដ្ឋបាលក្រុង ស្រុកនីមួយៗ អាចធ្វើឱ្យប៉ះពាល់ដល់ការកំណត់ពេលវេលាដើមគ្រាក្នុងការរៀបចំថវិកាប្រចាំឆ្នាំ ហើយកត្តានេះក៏អាចនឹងមានការពន្យាពេលក្នុងការផ្ទេរធនធានពីក្រសួងថ្នាក់ជាតិទៅដល់រដ្ឋបាលថ្នាក់ក្រុង ស្រុកផងដែរ តាមរយៈរតនាគារខេត្ត។ ប្រការនេះអាចនាំឱ្យមានការពន្យាពេលក្នុងការអនុវត្តគម្រោងផ្សេងៗ បើទោះបីរដ្ឋបាលក្រុង ស្រុកអាចខ្ចីថវិកាផ្សេងមកប្រើក្នុងពេលនោះក៏ដោយ ក៏ថវិកានោះបានគ្រាន់តែប្រើសម្រាប់ចំណាយលើប្រាក់ខែបុគ្គលិករបស់ខ្លួនប៉ុណ្ណោះ។

ប្រធាន និងសមាជិកក្រុមប្រឹក្សាភាគច្រើននៃគណៈកម្មាធិការដែលចូលរួមក្នុងការសម្ភាសន៍ (៨២%) ធ្លាប់មានបទពិសោធន៍ក្នុងការពិនិត្យពិច័យលើការអនុវត្តថវិការបស់ការិយាល័យក្រុង ស្រុករបស់ខ្លួន។ ពួកគេបានប្រើប្រាស់ ៣វិធីសាស្រ្ត ក្នុងការពិនិត្យពិច័យថវិកាពីញឹកញាប់ខ្លាំងទៅតិច រួមមាន i) ការលើកជាសំណួរទៅកាន់ប្រធានរដ្ឋបាល/ហិរញ្ញវត្ថុ ii) ការពិនិត្យមើលឡើងវិញនូវរបាយការណ៍លើការអនុវត្តថវិកាយ៉ាងទៀងទាត់ iii) លើកជាសំណួរទៅគណៈអភិបាល។ ដោយឡែក មានអ្នកផ្តល់សម្ភាសន៍តិចតួចដែលពុំធ្លាប់បានពិនិត្យពិច័យលើការអនុវត្តថវិកាបានផ្តល់ហេតុផលថា ដោយសារគាត់ពុំមានសមត្ថភាព ពុំទទួលបានព័ត៌មានគ្រប់គ្រាន់ (មិនទទួលបានរបាយការណ៍អនុវត្តថវិកាពេញលេញ) និងមិនមែនជាភារកិច្ចរបស់ខ្លួន។

អ្នកផ្តល់សម្ភាសន៍ ភាគច្រើនយល់ស្របអំពីសារៈសំខាន់នៃការធ្វើឱ្យព័ត៌មានថវិកាជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋ (៨៨% ជឿជាក់ថាវា *មានសារៈសំខាន់ខ្លាំង* ខណៈ ១២% ទៀតនិយាយថា *មានសារៈសំខាន់ខ្លះដែរ* )។ មានទស្សនៈយល់ឃើញថាលទ្ធភាពទទួលបានព័ត៌មានបែបនេះ គឺមានសារៈសំខាន់ជួយឱ្យប្រជាពលរដ្ឋបញ្ចេញមតិយោបល់របស់ខ្លួន និងជំរុញឱ្យពួកគាត់ចេះតាមដានការប្រើ

ប្រាស់ថវិកាក្រុង ស្រុក។ ទោះជាយ៉ាងណា សឹងពាក់កណ្ដាលនៃក្រុមប្រឹក្សា និងអភិបាលជឿជាក់ថា ប្រជាពលរដ្ឋមិនមានចំណាប់អារម្មណ៍ (៤៩%) និងមិនបានយល់ច្បាស់អំពីព័ត៌មានបានល្អ (៨៥%)។

# 5. ការរកឃើញស្ដីពីការយល់ដឹងលើទម្រង់ថវិកាប្រចាំឆ្នាំក្រុង ស្រុក

## 5.1. ការយល់ដឹងរបស់ប្រជាពលរដ្ឋ

អ្នកផ្ដល់សម្ភាសន៍ ៧ នាក់ក្នុងចំណោម ១០ នាក់យល់ឃើញថា មានការស្មុគស្មាញខ្លាំងពេកក្នុងការយល់ដឹងនៅទម្រង់ថវិកា [7] ដែលបានបង្ហាញដល់គាត់ពីសំណាក់ក្រុមប្រមូលទិន្នន័យ។ ប្រជាពលរដ្ឋប្រឈមនឹងកង្វះចំណេះដឹងខាងហិរញ្ញវត្ថុខ្លាំង ដូច្នេះហើយធ្វើឱ្យគាត់ខ្វះជំនាញមូលដ្ឋានក្នុងការអានទម្រង់ថវិកា ក៏ដូចជាយល់ដឹងសមាសធាតុផ្សេងៗនៃថវិកា។ ជាក់ស្ដែង មានតែ ៤% ប៉ុណ្ណោះនៃប្រជាពលរដ្ឋផ្ដល់សម្ភាសន៍ទទួលបាននូវការបណ្ដុះបណ្ដាល ឬមានបទពិសោធន៍ពាក់ព័ន្ធជាមួយនឹងហិរញ្ញវត្ថុ និងថវិកា។ ប្រជាពលរដ្ឋមួយចំនួនបានបដិសេធមិនផ្ដល់សម្ភាសន៍ដោយបាននិយាយថាពួកគាត់ពុំមានសមត្ថភាពឆ្លើយនឹងសំណួរបានឡើយ។

កម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋបានផ្ដល់សម្ភាសន៍មានលក្ខណៈស៊ីគ្នាទៅនឹងកម្រិតនៃការអប់រំដែលពួកគាត់ទទួលបាន ដូចបង្ហាញក្នុងរូប ៥.១។

*រូបភាព ៥.១៖ ការយល់ដឹងអំពីទម្រង់ថវិកាក្រុង ស្រុកទៅតាមកម្រិតនៃការអប់រំរបស់ប្រជាពលរដ្ឋ*




បុរសបានបង្ហាញថា មានការយល់ដឹងច្រើនបន្តិចជាងស្ត្រី។ ប្រជាពលរដ្ឋដែលយល់ឃើញថាទម្រង់ថវិកានោះ *ពិបាកយល់ខ្លាំង* គឺមានស្ត្រី ៧៦% និងបុរស ៧១% នៅខេត្តបាត់ដំបង ស្ត្រី ៨៦%

[7] ទម្រង់ថវិកាដែលបានបង្ហាញទៅកាន់ប្រជាពលរដ្ឋពីសំណាក់ក្រុមប្រមូលទិន្នន័យអាចរកបានក្នុងឯកសារភ្ជាប់មកជាមួយនៅឧបសម្ព័ន្ធទី ២។

និងបុរស ៦៣% នៅខេត្តប៉ៃលិន ស្ត្រី៧% និងបុរស ៧១% នៅខេត្តពោធិ៍សាត់។ ទោះជាយ៉ាងណា តួលេខនេះមិនគួរត្រូវបានគេគិតថាជាតួលេខពិតប្រាកដនោះទេ ដោយសារថានេះគ្រាន់តែជាការយល់ឃើញ និងចំណេះដឹងចេញពីស្វ័យវាយតម្លៃរបស់អ្នកផ្តល់សម្ភាសន៍តែប៉ុណ្ណោះ មិនមែនតាមរយៈការវាយតម្លៃជំនាញ និងមិនមែនតាមការធ្វើតេស្តដែលមានស្តង់ដារត្រឹមត្រូវនោះឡើយ។ ដូច្នេះ ទស្សនៈយល់ឃើញនៃចំណេះដឹងរបស់នរណាម្នាក់គឺទំនងមានការប្រែប្រួលដោយកត្តាផ្សេងៗ។ ឧទាហរណ៍ រដ្ឋបាលក្រុង ស្រុក និងអង្គការសង្គមស៊ីវិលមានប្រសាសន៍ថា ស្ត្រីទំនងជាមានការប្រុងប្រយ័ត្នខ្លួនឯងជាងបុរសដែលអាចនាំឱ្យពួកគេមើលស្រាលសមត្ថភាពរបស់ខ្លួន។

*រូបភាព ៥.២៖ ការយល់ដឹងអំពីថវិកាបែងចែកតាមយេនឌ័រ និងខេត្ត*

| | **បាត់ដំបង** | | **ប៉ៃលិន** | | **ពោធិ៍សាត់** | | **សរុប** | |
|---|---|---|---|---|---|---|---|---|
| | **បុរស** | **ស្ត្រី** | **បុរស** | **ស្ត្រី** | **បុរស** | **ស្ត្រី** | **បុរស** | **ស្ត្រី** |
| មិនយល់ | 71% | 76% | 63% | 86% | 71% | 57% | 69% | 74% |
| យល់បានខ្លះ | 21% | 15% | 16% | 7% | 14% | 31% | 18% | 17% |
| យល់បានយ៉ាងងាយ | 8% | 9% | 22% | 7% | 14% | 11% | 12% | 9% |

ផ្ទុយទៅវិញ មូលហេតុដូចៗគ្នាភាគច្រើនដែលអ្នកផ្តល់សម្ភាសន៍បានប្រាប់ថាមានការលំបាកខ្លះក្នុងការយល់ដឹងអំពីថវិកា គឺជាមូលហេតុខាងក្រៅ មិនមែនជាបញ្ហាទម្រង់ថវិកានោះទេ មូលហេតុទាំងនោះមានដូចជាកង្វះចំណេះដឹងហិរញ្ញវត្ថុ អនក្ខរកម្ម និងការពិតដែលថាពួកគាត់ពុំធ្លាប់ឃើញទម្រង់ថវិកាពីមុនមក។ ដោយឡែក បញ្ហាប្រឈមពាក់ព័ន្ធនឹងទម្រង់ថវិកាដូចបានបង្ហាញក្នុងរូបភាព ៥.៣ បានបញ្ជាក់ថា ទម្រង់ និងព័ត៌មាននៅក្នុងទម្រង់ថវិកាមានលក្ខណៈច្រើនពេកសម្រាប់អ្នកផ្តល់សម្ភាសន៍ ដែលក្នុងនោះមានព័ត៌មានច្រើនពេក វែងពេក ងាយច្រឡំ និងមិនរៀបរយល្អ។ អ្នកចូលរួមខ្លះទៀតក៏បានលើកឡើងថា ខ្លឹមសារទម្រង់ថវិកានេះមានលក្ខណៈបច្ចេកទេសខ្លាំង ហើយអ្នកខ្លះនិយាយថា ពួកគាត់ត្រូវការព័ត៌មាន និងការពន្យល់បន្ថែមទៀតដើម្បីអាចយល់ឯកសារនេះឱ្យបានត្រឹមត្រូវ។

*រូបភាព ៥.៣៖ បញ្ហាប្រឈមដែលធ្វើឱ្យប្រជាពលរដ្ឋពិបាកយល់លើទម្រង់ថវិកា*




*សម្គាល់៖ ទំហំនៃប្រអប់នីមួយៗខាងលើ តំណាងឱ្យភាពញឹកញាប់ដែលអ្នកផ្ដល់សម្ភាសន៍បានលើកពីបញ្ហាទាំងនោះ។*

ក្រៅពីផ្ដោតលើកម្រិតនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ ប្រជាពលរដ្ឋបានផ្ដល់មតិយោបល់ដើម្បីផ្លាស់ប្ដូរទម្រង់ថវិកាដែលអាចជួយសម្រួលដល់ការយល់ដឹងរបស់ពួកគាត់ផងដែរ។ មានប្រជាពលរដ្ឋតែ ៤០% ប៉ុណ្ណោះដែលបានចែករំលែកអនុសាសន៍របស់ខ្លួន ក្នុងនោះរួមមានសេចក្ដីសង្ខេបថវិកាទៅតាមខ្ទង់ចំណូលចំណាយនីមួយៗ និងផ្លាស់ប្ដូរទម្រង់ពិពណ៌នាអំពីព័ត៌មានដោយមានភ្ជាប់មកជាមួយនូវរូបភាព តារាង និងវីដេអូឱ្យបានច្រើនវិញ។

## 5.2. ការយល់ដឹងរបស់មន្ត្រីរដ្ឋបាលក្រុង ស្រុក

កម្រិតនៃការយល់ដឹងចំពោះទម្រង់ថវិកាប្រចាំឆ្នាំជាទូទៅនៅមានកម្រិត។ ភាគច្រើននៃអ្នកផ្ដល់សម្ភាសន៍ទទួលស្គាល់ថាពួកគាត់ពុំមានសមត្ថភាពពេញលេញ ដើម្បីយល់ដឹងអំពីគ្រប់ព័ត៌មានដែលបានបង្ហាញនៅលើទម្រង់នោះទេ។ មានតែនៅក្នុងក្រុង ស្រុកចំនួន ៤ ប៉ុណ្ណោះគឺ ក្រុងបាត់ដំបង ស្រុកគំរៀង ស្រុករតនមណ្ឌល និងក្រុងប៉ៃលិន ដែលអ្នកផ្ដល់សម្ភាសន៍ពាក់កណ្ដាលបានរាយការណ៍ថាមានការយល់ដឹងទម្រង់បានពេញលេញទាំងស្រុង។

*រូបភាព ៥.៤ សំណួរដែលបានសួរនៅក្នុងកិច្ចសម្ភាសន៍ក្រុង ស្រុក៖ តើលោកអ្នកបានយល់អំពីថវិកាប្រចាំឆ្នាំបានប៉ុណ្ណា? (n=57)*




ជាទូទៅ អ្នកដែលមិនមានការងារពាក់ព័ន្ធដោយផ្ទាល់ក្នុងការរៀបចំថវិកា ឬធ្វើការងារជាមួយនឹងរឿងថវិកា ពុំបានបង្ហាញកម្រិតនៃទំនុកចិត្តខ្លាំង ឬសមត្ថភាពខ្លាំងក្នុងការចូលរួមក្នុងដំណើរការរៀបចំថវិកាឡើយ។ ចំណេះដឹងរបស់អ្នកផ្តល់សម្ភាសន៍ជារឿយៗនៅមានកម្រិតត្រង់ចំណុចថវិកា (ចំណូល និងចំណាយ) ដែលស្ថិតក្រោមការទទួលខុសត្រូវ និងភារកិច្ចជាក់លាក់របស់ខ្លួន។ ហើយទោះបីជាអ្នកដែលធ្លាប់មានបទពិសោធន៍សិក្សា ឬបទពិសោធន៍ការងារជាមួយនឹងថវិកា ក៏បានរាយការណ៍ថាពួកគាត់ខ្វះចំណេះដឹង និងសមត្ថភាពខាងផ្នែកហិរញ្ញវត្ថុដែរ។

ទោះជាយ៉ាងណា មានលក្ខណៈខុសគ្នាយ៉ាងច្បាស់មួយរវាងអ្នកផ្តល់សម្ភាសន៍ដែលមានតួនាទីពាក់ព័ន្ធជាមួយនឹងហិរញ្ញវត្ថុ និងអ្នកផ្តល់សម្ភាសន៍ដទៃទៀត។ ប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ និងមន្ត្រីហិរញ្ញវត្ថុ គឺជាអ្នកមានចំណេះដឹងលើរឿងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុកជាងគេ ដោយពួកគាត់បានបង្ហាញពីសមត្ថភាព និងការយល់ដឹងច្បាស់ក្នុងការគ្រប់គ្រងថវិកាបានយ៉ាងល្អ។ ពួកគាត់គឺជាអ្នកប្រើប្រាស់និងចាត់ចែងថវិការជាក់ស្តែង ហើយទទួលបាននូវការបណ្តុះបណ្តាលក្នុងការរៀបចំថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុច្រើនជាងគេ។ នេះគឺជាករណីជាក់ស្តែងដែលកើតមានឡើងគ្រប់ក្រុង ស្រុក។

ដោយឡែក ក្រុមប្រឹក្សាក្រុង ស្រុកប្រឈមនឹងគម្លាតចំណេះដឹងចម្បង ដើម្បីយល់ដឹងអំពីទម្រង់ និងខ្លឹមសារថវិកា ហើយជំនាញគ្រប់គ្រងថវិការបស់ពួកគាត់នៅតែមានកម្រិតទាបដដែល។

តាមពិតប្រធានក្រុមប្រឹក្សាទាំង ៣ ដែលបានសម្ភាសន៍បានរាយការណ៍ថា *បានយល់យ៉ាងពេញលេញ* អំពីទម្រង់ថវិកា ខណៈប្រធានក្រុមប្រឹក្សា ៦ រូបទៀតមានប្រសាសន៍ថា *អាចយល់បានខ្លះតែប៉ុណ្ណោះ*។ តួនាទីរបស់ក្រុមប្រឹក្សានៅមានកម្រិតក្នុងការអនុម័តសេចក្តីព្រាងថវិកា ដែលជារឿយៗនាំឱ្យក្រុមប្រឹក្សាអនុម័តផែនការថវិកាដោយពុំបានយល់ដឹងពេញលេញទាំងស្រុង នេះបើតាមប្រសាសន៍របស់តំណាងម្នាក់របស់អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប។ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក និងអ្នកផ្តល់សម្ភាសន៍ ដែលទើបតែត្រូវបានតែងតាំងចូលកាន់តំណែងថ្មីៗ មានការយល់ដឹងទាបខ្លាំង ហើយពួកគាត់ត្រូវការពេលវេលាបន្ថែមដើម្បីឱ្យចេះស្ទាត់ចំពោះទម្រង់ថវិកា និងដំណើរការនៃការរៀបចំថវិកាប្រចាំឆ្នាំ។

អ្នកដែលមានការយល់ដឹងទាបជាងគេបំផុត គឺជាសមាជិកគណៈកម្មាធិការក្រុមប្រឹក្សា។ ក្នុងចំណោមសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសចំនួន ១០ រូប មានតែ ២ រូបប៉ុណ្ណោះដែល *យល់ដឹងបានពេញលេញ* អំពីទម្រង់ថវិកា ហើយ ៨ រូបទៀត *យល់ដឹងបានខ្លះ*។ ក្នុងចំណោមសមាជិកគណៈកម្មាធិការលទ្ធកម្មមាន ៤ រូប *យល់ដឹងបានពេញលេញ* និង ៧ រូប *យល់ដឹងបានខ្លះ*។ ចំពោះអ្នកដែលយល់ដឹងតិចបំផុត គ្មានសមាជិកនៃ គ.ក.ស.ក ណាម្នាក់បានរាយការណ៍ថាអាចយល់ដឹងអំពីទម្រង់ថវិកាបានពេញលេញឡើយ (១២រូប *យល់បានខ្លះ* និង១រូប *មិនយល់ភាគច្រើន*)។

បញ្ហាប្រឈមដែលរារាំងការយល់ដឹងអំពីថវិកាប្រចាំឆ្នាំរបស់មន្ត្រីរដ្ឋបាលក្រុង ស្រុក គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងបញ្ហានានាដែលប្រជាពលរដ្ឋប្រឈមដែរ។ ទម្រង់ថវិកាបច្ចុប្បន្នមានលក្ខណៈវែង ស្មុគស្មាញ និងព័ត៌មានលម្អិតច្រើនពេក ជាមួយនឹងពាក្យបច្ចេកទេសខាងហិរញ្ញវត្ថុយ៉ាងច្រើន។ អ្នកផ្តល់សម្ភាសន៍ជាច្រើនពុំស្គាល់វាក្យស័ព្ទហិរញ្ញវត្ថុភាគច្រើន ហើយបានពន្យល់ថាទោះបីជាក្រោយពេលទទួលបានការពន្យល់សមរម្យពីប្រធានរដ្ឋបាល និងហិរញ្ញវត្ថុ ឬប្រធានក្រុមប្រឹក្សាយ៉ាងណាក៏ដោយ ក៏ពួកគាត់ជាច្រើននៅតែពុំយល់បានពេញលេញ។ សំណូមពរដែលបានលើកឡើងដើម្បីកែលម្អទម្រង់ថវិកាប្រចាំឆ្នាំមាន៖

- ការដាក់បញ្ចូល កំណត់សម្គាល់ពន្យល់លម្អិត និងចំៗ បញ្ជាក់អំពី៖ អត្ថន័យនៃជំពូក និងថវិកា និងខ្ទង់ចំណាយ ចំណូលផ្សេងៗគ្នាទៅតាមជំពូកនីមួយៗ។
- កាត់បន្ថយចំនួនលេខកូដ និងជំពូក។
- ពាក់ព័ន្ធនឹងទម្រង់វិញ ពុម្ពអក្សរគួរធំៗ ពីព្រោះអក្សរតូចពេកអ្នកអានពិបាកមើល។

## *របាយការណ៍អង្កេតស្តីពីលទ្ធភាពទទួលបាន និងការយល់ដឹងលើថវិកាក្រុង ស្រុក*

ដោយសារការយល់ដឹងមានដែនកំណត់នេះ និងអង្គហេតុដែលថាមិនមានការយល់ដឹងពេញលេញអំពីថវិកាប្រចាំឆ្នាំ ធ្វើឱ្យអ្នកផ្តល់សម្ភាសន៍មានសមត្ថភាពមានកម្រិតក្នុងការផ្តល់ជាធាតុចូលក្នុងអំឡុងពេលរៀបចំ និងដំណើរការអនុវត្តថវិកា។ ដើម្បីជួយសម្រួលដល់ចំណុចនេះ អ្នកផ្តល់សម្ភាសន៍មួយចំនួនស្នើឱ្យទទួលបានទម្រង់ថវិកាប៉ុន្មានថ្ងៃមុននឹងមានកិច្ចប្រជុំក្រុមប្រឹក្សា ជាជាងការទទួលបានក្នុងពេលប្រជុំតែម្តង ដើម្បីអនុញ្ញាតឱ្យពួកគាត់មានពេលគ្រប់គ្រាន់ក្នុងការអាន និងបញ្ជាក់អំពីចម្ងល់របស់ខ្លួន។

ពាក់ព័ន្ធនឹងសមត្ថភាព និងចំណេះដឹងរបស់ប្រជាពលរដ្ឋវិញ រដ្ឋបាលក្រុង ស្រុកបានបញ្ជាក់ និងបង្ហាញថា ពួកគាត់ដឹងថាប្រជាពលរដ្ឋមិនមានចំណេះដឹងខាងហិរញ្ញវត្ថុទេ។ តំណាងម្នាក់មកពីអគ្គនាយកដ្ឋានថវិការដ្ឋបាលថ្នាក់ក្រោមជាតិបានមានប្រសាសន៍ថា ប្រជាពលរដ្ឋយល់ដឹងអំពីថវិកាខេត្តច្រើនជាងថវិកាក្រុង ស្រុក ពីព្រោះពួកគាត់ចាប់អារម្មណ៍ខ្លាំងតែទៅលើគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធធំៗ ដូចជាផ្លូវថ្នល់ និងប្រឡាយជាដើម។

*រូបភាព ៥.៥៖ ទស្សនៈនានាស្តីពីសមត្ថភាពរបស់ប្រជាពលរដ្ឋក្នុងការយល់ដឹងលើទម្រង់ថវិកាប្រចាំឆ្នាំក្រុង ស្រុក (n=66)*



## 6. ការរកឃើញស្តីពីការផ្សព្វផ្សាយព័ត៌មានអំពីថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ

នៅក្នុងផ្នែកនេះ យើងនឹងពិនិត្យមើលទាំងផ្នែកអ្នកផ្តល់សេវា និងអ្នកទទួលសេវានៃព័ត៌មានថវិកា។ ផ្នែកម្ខាងជាអ្នកត្រួតពិនិត្យការផ្សព្វផ្សាយការអនុវត្តរបស់រដ្ឋបាល និងឱកាសសម្រាប់ឱ្យសាធារណជនចូលរួម ផ្នែកម្ខាងទៀតអនុញ្ញាតឱ្យស្វែងយល់ ទៅនឹងឥរិយាបថរបស់ប្រជាពលរដ្ឋចំពោះការផ្សាព្វផ្សាយថវិកា និងការចូលរួមក្នុងកិច្ចការសាធារណៈ។ ការរកឃើញបានកំណត់បញ្ហាចម្បងៗ ចំនួន ៧ ពាក់ព័ន្ធនឹងការចូលរួមរបស់សាធារណជនមានកម្រិតទាប និងការរារាំងព័ត៌មានឱ្យជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

យោងតាមអ្នកផ្តល់សម្ភាសន៍នៅក្រុង ស្រុកភាគច្រើន រដ្ឋបាលក្រុង ស្រុកមានរៀបចំផែនការយុទ្ធសាស្រ្តសម្រាប់ការប្រាស្រ័យទាក់ទងក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ហើយយោងតាមអ្នកផ្តល់សម្ភាសន៍៧៨% មានប្រសាសន៍ថា ការផ្សព្វផ្សាយព័ត៌មានអំពីថវិកាមានដាក់នៅក្នុងផែនការនេះដែរ។ ជាក់ស្តែង យោងតាមលេខាធិការដ្ឋាន គ.ជ.អ.ប ការផ្សព្វផ្សាយព័ត៌មានអំពីថវិកាមានការកែលម្អគួរឱ្យកត់សម្គាល់ ជាពិសេសស្ថិតក្រោមការអនុវត្ត I-SAF ។ ការអនុវត្តផ្សព្វផ្សាយព័ត៌មានរួមមានតាមរយៈ៖ សកម្មភាពដោយផ្ទាល់ (ដូចជាវេទិកាសាធារណៈ កិច្ចប្រជុំក្រុមប្រឹក្សា និងកិច្ចប្រជុំពិគ្រោះយោបល់) ក្តារព័ត៌មានសាធារណៈ ព័ត៌មានផ្សព្វផ្សាយតាមរយៈឧគ្ឃោសនាស័ព្ទនៅលើរ៉ឺម៉កកង់បី និងកម្មវិធីវិទ្យុ។ មេឃុំ និងរដ្ឋបាលឃុំត្រូវបានគេចាត់ទុកថាជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជូនដំណឹងដល់ប្រជាពលរដ្ឋ។

*រូបភាព ៦.១៖ សំណួរសួរទៅកាន់រដ្ឋបាលក្រុង ស្រុក៖ តើរដ្ឋបាលរបស់អស់លោក លោកស្រីមានយុទ្ធសាស្រ្តប្រាស្រ័យទាក់ទង ដើម្បីផ្សព្វផ្សាយព័ត៌មានសាធារណៈដែរឬទេ? (n=69)*

*របាយការណ៍អង្កេតស្ដីពីលទ្ធភាពទទួលបាន និងការយល់ដឹងលើថវិកាក្រុង ស្រុក*




ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋនៅតែទទួលបានព័ត៌មានតិចតួចអំពីថវិកាប្រចាំឆ្នាំរបស់រដ្ឋ បាលក្រុង ស្រុករបស់ខ្លួន។ មានប្រជាពលរដ្ឋតែចំនួន ២% ប៉ុណ្ណោះធ្លាប់បានឃើញថវិកាប្រចាំឆ្នាំរដ្ឋបាលក្រុង ស្រុករបស់ខ្លួន ហើយមានតែ ៣% ប៉ុណ្ណោះធ្លាប់ឃើញ ឬធ្លាប់ទទួលបានឯកសារអប់រំដែលបង្ហាញព័ត៌មានអំពីរដ្ឋបាលក្រុង ស្រុករបស់ខ្លួន តាមរយៈដូចជាខិតប័ណ្ណ ផ្ទាំងផ្សព្វផ្សាយ និងវីដេអូ។ ទោះយ៉ាងណា ប្រជាពលរដ្ឋបានបង្ហាញអំពីចំណាប់អារម្មណ៍ខ្លាំងក្នុងការយល់ដឹងបន្ថែមអំពីថវិកាក្រុង ស្រុក ជាពិសេសអំពីការវិភាជន៍ថវិកា និងការចំណាយ។

*រូបភាព ៦.២ សំណួរសួរទៅប្រជាពលរដ្ឋ៖ ហេតុអ្វីបានជាលោកអ្នកពុំធ្លាប់ឃើញឯកសារណាមួយដែលមានព័ត៌មានអំពីថវិកាក្រុង ស្រុក? (n=334, អនុញ្ញាតឱ្យឆ្លើយបានច្រើន)*




## បញ្ហាទី ១៖ ព័ត៌មានថវិកាមិនបានត្រៀមជាស្រេចសម្រាប់ប្រជាពលរដ្ឋ

យោងតាមប្រជាពលរដ្ឋ មូលហេតុសំខាន់ដែលមិនធ្លាប់ឃើញព័ត៌មានអំពីថវិកាប្រចាំឆ្នាំក្រុង ស្រុកគឺថា មិនមានផ្សព្វផ្សាយជាព័ត៌មានទេ។ តាមច្បាប់ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានភារកិច្ចធ្វើឱ្យព័ត៌មានសាធារណៈដែលពាក់ព័ន្ធជ្រួតជ្រាបដល់ប្រជាពលរដ្ឋ។

ក្រុមប្រឹក្សាម្នាក់ត្រូវតែធ្វើអ្វីដែលខ្លួនអាចធ្វើបានដើម្បីធានាថាសាធារណជនមានលទ្ធភាពទទួលបានព័ត៌មានដូចជា៖ របៀបវារៈក្រុមប្រឹក្សា កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សា លក្ខន្តិកៈក្រុមប្រឹក្សា ផែនការអភិវឌ្ឍរបស់ក្រុមប្រឹក្សា និងឯកសារសំខាន់ៗដទៃទៀត (ច្បាប់រៀបចំអង្គការមាត្រា ៤១, ៥១ គំរូបទបញ្ជាផ្ទៃក្នុង មាត្រា ២ និងមាត្រា៦)

គ្រប់ក្រុមប្រឹក្សាត្រូវតែពិចារណាក្នុងគ្រប់កិច្ចប្រជុំអំពីវិធីផ្សព្វផ្សាយព័ត៌មានទៅកាន់ប្រជាពលរដ្ឋរបស់ខ្លួន (អនុក្រឹតស្តីពីតួនាទី – ខេត្ត មាត្រា ១៤ មាត្រា៧០ និងមាត្រា១៣២)។

ច្បាប់ក៏បានចែងផងដែរថា "រដ្ឋបាលត្រូវតែរៀបចំ ក្តារព័ត៌មានសាធារណៈដែលងាយស្រួលមើលឃើញដាក់ពីមុខការិយាល័យរដ្ឋបាល។ ព័ត៌មានត្រូវបង្ហាញអំពីព័ត៌មានក្រុមប្រឹក្សាផ្លូវការរយៈ

ពេល ១០ ថ្ងៃយ៉ាងតិច។ លើសពីនេះ ក្រុមប្រឹក្សាត្រូវរៀបចំក្ដារព័ត៌មាននៅទីសាធារណៈផ្សេងទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានបន្ថែមទៀតដល់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាក៏ត្រូវស្វែងរកមធ្យោបាយផ្សេងទៀត ដើម្បីផ្សព្វផ្សាយព័ត៌មានជូនប្រជាជនអំពីការងាររបស់រដ្ឋបាលផងដែរ" (អនុក្រឹតស្ដីពីតួនាទី – ខេត្ត មាត្រា ៥៤ មាត្រា១១១ និងមាត្រា១៧២)។

ក្នុងការអនុវត្តជាក់ស្ដែង ទោះមានក្ដារព័ត៌មានសាធារណៈដាក់តាំងនៅច្រកចូលនៃរដ្ឋបាលក្រុង ស្រុកទាំង ១១ យ៉ាងណាក៏ដោយ ក៏គ្មានក្ដារព័ត៌មានណាមានបិទទម្រង់ថវិកាប្រចាំឆ្នាំដែរ ក្នុងពេលក្រុមការងារចុះស្រាវជ្រាវនៅតាមក្រុង ស្រុក។ ក្ដារព័ត៌មានសាធារណៈ មិនបានបង្ហាញឯកសារផ្សេងៗទៀតឡើយ ដូចជាប្រតិទិនប្រជុំក្រុមប្រឹក្សា ការសម្រេចចិត្តដែលអនុម័តដោយក្រុមប្រឹក្សា ព័ត៌មានអំពីសេវាកម្មដែលបានផ្ដល់តាមរយៈការិយាល័យច្រកចេញចូលតែមួយ និងព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតក្រុមប្រឹក្សា និងដំណើរការបោះឆ្នោត។ ទោះជាយ៉ាងណា ឯកសារបែបនេះគឺជារឿយៗហួសសម័យ ឬស្ថិតក្នុងស្ថានភាពអាក្រក់ដែលធ្វើឱ្យគេពិបាកអាន។

ប្រមាណ ៥០% នៃអ្នកផ្ដល់សម្ភាសន៍ក្រុង ស្រុកមានប្រសាសន៍ថា សេចក្ដីព្រាងថវិកាប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយជាសាធារណៈ (ដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹតលេខ ១៧២) ហើយមានតែ ៣១% ប៉ុណ្ណោះមានប្រសាសន៍ថា រដ្ឋបាលរបស់ខ្លួនបានផ្សព្វផ្សាយថវិកាប្រចាំឆ្នាំដែលមានការអនុម័តរួច។ វិធីសាស្ត្រផ្សព្វផ្សាយព័ត៌មានដែលបានលើកឡើងខាងលើ គឺក្ដារព័ត៌មានសាធារណៈដាក់តាំងក្នុងទីសាធារណៈនានា សាលាឃុំ មេឃុំ វេទិកាសាធារណៈ និងកិច្ចប្រជុំក្រុមប្រឹក្សា។

*រូបភាព ៦.៣ សំណួរសួរទៅកាន់រដ្ឋបាលក្រុង ស្រុក៖ តើសេចក្ដីព្រាងថវិកាប្រចាំឆ្នាំត្រូវបានផ្សព្វផ្សាយទៅកាន់សាធារណជនដែរឬទេ? (n=49)*



*រូបភាព ៦.៤ សំណួរសួរទៅកាន់រដ្ឋបាលក្រុង ស្រុក៖ តើថវិកាប្រចាំឆ្នាំដែលបានអនុម័តរួចត្រូវបានផ្សព្វផ្សាយទៅកាន់សាធារណៈជនដែរឬទេ? (n=46)*




**បញ្ហាទី ២៖ រដ្ឋបាលក្រុង ស្រុកខ្វះធនធានហិរញ្ញវត្ថុដើម្បីផលិតឯកសារផ្សព្វផ្សាយព័ត៌មាន**

ទម្រង់ថវិកាបច្ចុប្បន្នគឺមិនមែនជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការជូនដំណឹងដល់សាធារណជនឡើយ ដោយសារតែវាមានភាពស្មុគស្មាញ និងកម្រិតនៃការអប់រំទាប ដូចដែលបានឃើញនៅក្នុងសំណាកនៃការអង្កេតនេះស្រាប់ ប្រជាពលរដ្ឋមិនមានសមត្ថភាពក្នុងការយល់ និងមិនបានអាន ទោះបីមានឯកសារសម្រាប់អានក៏ដោយ។ ដូច្នេះ សំណៅទម្រង់ថវិកាដែលត្រូវបានគេកែសម្រួល និងងាយយល់ជាងមុននឹងជំរុញលទ្ធភាពទទួលបានព័ត៌មានអំពីថវិកា និងជួយសម្រួលការយល់ដឹងរបស់ប្រជាពលរដ្ឋកាន់តែច្រើន (ព័ត៌មានបន្ថែមមាននៅក្នុងផ្នែកអនុសាសន៍)។

ក្រៅពីនេះ ការផលិតឯកសារព័ត៌មាន អប់រំ និងទំនាក់ទំនង (IEC) អំពីថវិកា គឺពុំទាន់គ្រប់គ្រាន់នៅឡើយ។ ហេតុនេះ វាចាំបាច់ត្រូវមានទម្រង់គំរូថវិកាដែលមានលក្ខណៈងាយស្រួលយល់ជាងនេះ ដោយត្រូវគិតគូរពីកម្រិតយល់ដឹងខាងផ្នែកហិរញ្ញវត្ថុរបស់សាធារណជនដើម្បីបង្ហាញព័ត៌មានថវិកាដល់ប្រជាពលរដ្ឋ។ ទោះជាយ៉ាងណា កង្វះធនធានហិរញ្ញវត្ថុធ្វើឱ្យរដ្ឋបាលក្រុង ស្រុកមិនមានលទ្ធភាពផលិតឯកសារផ្សព្វផ្សាយ និងរៀបចំសកម្មភាពផ្សព្វផ្សាយនានាឡើយ។ មិនមានខ្ទង់ថវិកាណាដើម្បីចំណាយលើការផ្សព្វផ្សាយព័ត៌មាន និងធ្វើការងារជាមួយប្រជាពលរដ្ឋទេ។

ដូចឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិបានពន្យល់ថា ព័ត៌មានថវិកាក្រុង ស្រុកមានជាលក្ខណៈអនឡាញលើគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប៉ុន្តែក្រសួងមិនមានថវិកាគ្រប់គ្រាន់ក្នុងការផលិតឯកសារព័ត៌មានគ្រប់ប្រភេទឡើយ។ ទោះជាយ៉ាងណា រដ្ឋបាលក្រុង ស្រុកត្រូវបានលើកទឹកចិត្តឱ្យផលិតឯកសារបែបនេះ តាមរយៈការទទួលថវិកាបន្ថែម ប្រសិនបើពួកគាត់បិទផ្សាយថវិកានៅលើក្តារព័ត៌មានសាធារណៈ ដូចមានចែងនៅក្នុងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF)។ យោងតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋបាលក្រុង ស្រុកប្រមាណ ៤៥ បានទទួលថវិកាបន្ថែមនេះរួចទៅហើយ ទោះបីជាក្រសួងបានទទួលស្គាល់ថាវានៅពុំទាន់គ្រប់គ្រាន់ក្នុងការផលិតឯកសារស្តីពីថវិកាយ៉ាងណាក៏ដោយ។ ការពិតដែលថាកង្វះធនធានហិរញ្ញវត្ថុគឺជាបញ្ហាប្រឈមដ៏ចម្បងមួយក្នុងការផ្សព្វផ្សាយព័ត៌មាន គឺត្រូវបានបញ្ជាក់ដោយអ្នកចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់នៅខេត្តបាត់ដំបង ដែលពួកគាត់បានសំណូមពរឱ្យបញ្ចូលខ្ទង់ថវិកាដើម្បីអាចប្រើប្រាស់សម្រាប់ការចំណាយបែបនោះ។

## បញ្ហាទី ៣៖ ប្រជាពលរដ្ឋកម្រអញ្ជើញមកការិយាល័យក្រុង ស្រុក

ប្រជាពលរដ្ឋចូលរួមក្នុងការអង្កេតប្រមាណពាក់កណ្តាលធ្លាប់ទៅកាន់ការិយាល័យក្រុង ស្រុករបស់ខ្លួនយ៉ាងហោចម្តងក្នុងមួយជីវិត។ រូបភាព ៦.៥ បង្ហាញពីភាគរយនៃអ្នកផ្តល់សម្ភាសន៍តាមយេនឌ័រ និងបណ្តាខេត្តនីមួយៗដែលធ្លាប់អញ្ជើញទៅការិយាល័យក្រុង ស្រុកម្តងយ៉ាងតិច។ ខេត្តបាត់ដំបងបានបង្ហាញថា មានតួលេខខ្ពស់ជាង គឺជាង៥០% ទាំងបុរសទាំងស្ត្រី។ តួលេខទាបជាងគេ គឺនៅក្នុងខេត្តប៉ៃលិនដែលត្រឹមតែ ១/៤ នៃស្ត្រីទាំងអស់បានរាយការណ៍ថាធ្លាប់អញ្ជើញទៅការិយាល័យក្រុង ស្រុក។

*រូបភាព ៦.៥៖ ភាគរយអ្នកផ្តល់សម្ភាសន៍ដែលធ្លាប់ទៅកាន់ការិយាល័យក្រុង ស្រុកនៅតាមបណ្តាខេត្ត និងយេនឌ័រ*

| | | |
|---|---|---|
| 50% | បាត់ដំបង | 57% |
| 25% | ប៉ៃលិន | 53% |
| 43% | ពោធិ៍សាត់ | 36% |

ការយល់ដឹងពីមូលហេតុនៅខាងក្រោយតួលេខនៃការអញ្ជើញទៅការិយាល័យក្រុង ស្រុកនេះមានសារៈសំខាន់ណាស់។ ចម្ងាយរវាងលំនៅដ្ឋានអ្នកផ្តល់សម្ភាសន៍ និងការិយាល័យក្រុង ស្រុក មិនទំនងជាកត្តាកំណត់ឡើយ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋបានលើកឡើងថា មិនមានពេលដោយសារកាលវិភាគរវល់ពេក ម៉ោងធ្វើការយូរ ភារកិច្ចមើលថែកូនចៅ និងគ្រួសារ។ យោងតាមមន្ត្រីក្រុង ស្រុកថា

ប្រជាពលរដ្ឋអញ្ជើញមកការិយាល័យក្រុង ស្រុកតែនៅពេលណាពួកគាត់ត្រូវការជំនួយដោះស្រាយបញ្ហាជាក់លាក់ណាមួយដែលប៉ះពាល់លើគាត់ដោយផ្ទាល់តែប៉ុណ្ណោះ។

**បញ្ហាទី ៤៖ តួនាទីអង្គការសង្គមស៊ីវិលនៅមានកម្រិតក្នុងការផ្សព្វផ្សាយថវិកាក្រុង ស្រុក**

តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការផលិត ផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីថវិកាក្រុង ស្រុកនៅមានកម្រិតនៅឡើយ។ នៅក្រុងបាត់ដំបង អង្គការមិនមែនរដ្ឋាភិបាលជួយគាំទ្រកសាងសមត្ថភាពបច្ចេកទេសរបស់រដ្ឋបាល និងផលិតឯកសារអប់រំពាក់ព័ន្ធនឹងថវិកា។ ស្រុកបាណន់ធ្វើការជាមួយអង្គការការីតាស់ ទឹកចិត្តម្ដាយ ធីភីអូ និងអង្គការបន្ទាយស្រី ប៉ុន្តែមិនមែនពាក់ព័ន្ធនឹងរឿងថវិកាទេ។ មន្ត្រី និងក្រុមប្រឹក្សាក្រុង ស្រុកបានវាយតម្លៃថា កិច្ចសហប្រតិបត្តិការដែលមានស្រាប់ មានភាពវិជ្ជមានខ្លាំង គឺពិន្ទុរវាង ៤ និង ៥ លើ ៥ លើកលែងតែអ្នកចូលរួមម្នាក់នៅស្រុកបាកានដែលគាត់ឱ្យពិន្ទុ ២ លើ ៥។

នៅថ្នាក់ឃុំ សង្កាត់ អង្គការសង្គមស៊ីវិលក៏មានតួនាទីយ៉ាងសកម្មក្នុងការពង្រឹងភាពអង់អាចរបស់ប្រជាពលរដ្ឋ និងលើកទឹកចិត្តក្នុងការចូលរួមរបស់ពួកគាត់ទៅលើកិច្ចការងារសាធារណៈផងដែរ។ អង្គការសង្គមស៊ីវិលប្រើប្រាស់បទពិសោធន៍របស់ខ្លួនធ្វើការជាមួយសហគមន៍ ដើម្បីពាំនាំសេចក្ដីត្រូវការ សំណើ និងសំណួររបស់ប្រជាពលរដ្ឋទៅកាន់រដ្ឋបាល។ ចេញពីបទពិសោធន៍វិជ្ជមាននៅថ្នាក់ឃុំ សង្កាត់ មន្ត្រីក្រុង ស្រុកភាគច្រើនដែលបានចូលរួមក្នុងកិច្ចពិភាក្សាក្រុមគោលដៅ ជឿជាក់ថាការធ្វើការជាមួយអង្គការសង្គមស៊ីវិលឱ្យបានច្រើនក្នុងការផ្សព្វផ្សាយព័ត៌មានអំពីថវិកានឹងអាចជួយរួមចំណែកធ្វើឱ្យសាធារណជនទទួលព័ត៌មានបានល្អជាងមុន និងចូលរួមកាន់តែច្រើន។

**បញ្ហាទី ៥៖ ការមិនយល់ដឹងខ្លាំងក្នុងការអាចមានលទ្ធភាពទទួលបានថវិកាក្រុង ស្រុក**

ឧបសគ្គដ៏ចម្បងចំពោះព័ត៌មានថវិកា គឺការកង្វះការយល់ដឹងជាទូទៅអំពីរបៀប និងទីកន្លែងទទួលបានព័ត៌មាននោះ ជាពិសេសក្នុងចំណោមស្ត្រី។ ដូចដែលបានលើកឡើងនៅក្នុងទំព័រខាងលើ ប្រជាពលរដ្ឋសឹងតែ ៨០% មិនអាចប្រាប់បានថាតើថវិការដ្ឋបាលក្រុង ស្រុករបស់ខ្លួនមានផ្សព្វផ្សាយជាសាធារណៈដែរឬទេ។ បន្ថែមលើនេះ ពួកគាត់ភាគច្រើនមិនដឹងថាតើក្ដារព័ត៌មានជាសាធារណៈនោះដាក់នៅកន្លែងណាទេក្នុងការិយាល័យក្រុង ស្រុក។ សូម្បីក្នុងចំណោមអ្នកដែលធ្លាប់អញ្ជើញទៅការិយាល័យក្រុង ស្រុក មានតែខ្លះប៉ុណ្ណោះដែលរាយការណ៍ថា ធ្លាប់បានឃើញ (៣៦% នៅខេត្តបាត់ដំបង ៣៨% នៅខេត្តប៉ៃលិន និង៦៨% នៅខេត្តពោធិ៍សាត់) ខណៈដែលមាន ៦១% នៅខេត្តបាត់ដំបង ៦៣% នៅខេត្តប៉ៃលិន និង ៣២% នៅខេត្តពោធិ៍សាត់ និយាយថា គាត់មិនដឹងច្បាស់ដែរ។

ប្រជាពលរដ្ឋអាចមានលទ្ធភាពទទួលបានព័ត៌មានថវិកាជាសំណៅរឹងនៅឯការិយាល័យក្រុង ស្រុក។ យោងតាមច្បាប់ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវតែបើកចំហក្នុងអំឡុងពេលម៉ោងធ្វើការផ្លូវការ ដើម្បីឱ្យប្រជាពលរដ្ឋអាចចូលទំនាក់ទំនងជាមួយក្រុមប្រឹក្សា និងគណៈអភិបាល ទទួលព័ត៌មានពីរដ្ឋបាល និងផ្តល់មតិ ឬសំណូមពរទៅលើបញ្ហាណាមួយបាន (អនុក្រឹតស្តីពីតួនាទី – ខេត្ត, មាត្រា ៥០ មាត្រា១០៧ និងមាត្រា១៦៨)។ ទោះជាយ៉ាងណា ប្រជាពលរដ្ឋភាគច្រើន ទោះបីជាគាត់ធ្លាប់អញ្ជើញទៅការិយាល័យក្រុង ស្រុកក៏ដោយ ក៏មិនអាចប្រាប់ថាតើការិយាល័យក្រុង ស្រុករបស់ខ្លួនមានផ្តល់ជំនួយបែបនេះឡើយ (៧១% នៅខេត្តបាត់ដំបង ១០០% នៅខេត្តប៉ៃលិន និង ១២% នៅខេត្តពោធិ៍សាត់)។ បុគ្គលិក និងក្រុមប្រឹក្សាក្រុង ស្រុក បានបញ្ជាក់ថា ប្រជាពលរដ្ឋពុំធ្លាប់បានស្នើសុំព័ត៌មានថវិកាដែលគាត់អាចសុំមើលបានយ៉ាងងាយ និងឥតគិតថ្លៃនៅឯការិយាល័យស្រុក ឬអង្គភាពថវិកានោះទេ។

មធ្យោបាយម៉្យាងទៀតក្នុងការទទួលបានព័ត៌មានក្រុង ស្រុក គឺទទួលដោយផ្ទាល់ពីតំណាងរដ្ឋបាល ឬអ្នកពាក់ព័ន្ធផ្សេងទៀត។ នៅពេលមានការសួរប្រជាពលរដ្ឋថាតើនរណាដែលពួកគាត់នឹងស្នើសុំក្នុងករណីគាត់ចង់ទទួលបានព័ត៌មានបន្ថែមអំពីថវិកាក្រុង ស្រុក ហើយក្រុមការងារស្រាវជ្រាវបានជូនបញ្ជីចម្លើយឱ្យពួកគាត់ជ្រើសរើសចម្លើយជាច្រើន។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ តំណាងក្រុង ស្រុក មិនស្ថិតក្នុងចំណោមមនុស្សដែលជាជម្រើសប្រជាពលរដ្ឋចាប់យកច្រើនជាងគេនោះឡើយ។ ប្រជាពលរដ្ឋភាគច្រើន (៧៣%) មានប្រសាសន៍ថា ពួកគាត់នឹងស្នើសុំព័ត៌មានអំពីថវិកាក្រុង ស្រុកពីសំណាក់មេភូមិ ហើយបន្ទាប់មកសុំពីមេឃុំ (៦២%)។ ចំណែកទាបជាងគួរឱ្យកត់សម្គាល់នៃប្រជាពលរដ្ឋ (២៧%) ជ្រើសរើសជម្រើសសួរអ្នកស្គាល់គ្នា ខណៈមានតែ ២៣% នៃប្រជាពលរដ្ឋប៉ុណ្ណោះដែលនឹងសួរក្រុមប្រឹក្សាក្រុង ស្រុក និង ១៥% នឹងសួរមន្ត្រីក្រុង ស្រុក[៨]។ ប្រការនេះ អាចបញ្ជាក់អំពីទំហំនៃបញ្ហាដទៃទៀត ដូចជាកង្វះជំនឿចិត្ត ឬការចូលរួមមានកម្រិតរបស់រដ្ឋបាលក្រុង ស្រុកក្នុងសកម្មភាពមូលដ្ឋាន ដែលចំណុចនេះមានលក្ខណៈសំខាន់ដើម្បីស្វែងយល់បន្ថែមនៅក្នុងការស្រាវជ្រាវបន្ថែមលើកក្រោយ ។

## បញ្ហាទី ៦៖ ការចូលរួមមានកម្រិតក្នុងកិច្ចប្រជុំជាសាធារណៈ

ប្រជាពលរដ្ឋដែលបានចូលរួមក្នុងកិច្ចប្រជុំរៀបចំដោយរដ្ឋបាលក្រុង ស្រុកគឺមានកម្រិតទាបយ៉ាងច្បាស់ក្រឡែត។ ទោះបីជា ៣ ភាគ ៤ នៃប្រជាពលរដ្ឋបានដឹងអំពីសិទ្ធិរបស់ខ្លួនក្នុងការចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុកប្រចាំខែយ៉ាងណាក៏ដោយ ក៏ក្នុងចំណោម ១០ នាក់ មានប្រជាពលរដ្ឋ

[៨] សម្គាល់ថាក្រុមប្រឹក្សាឃុំសង្កាត់ មិនត្រូវបានគេដាក់បញ្ចូលក្នុងបញ្ជីដែលបង្ហាញជូនប្រជាពលរដ្ឋឡើយ។

ម្នាក់ប៉ុណ្ណោះដែលធ្លាប់ចូលរួមម្តង។ មានហេតុផលចម្បងចំនួន ៣ ដែលបានរាយការណ៍ថា ក្រុមប្រឹក្សាមិនបានប្រកាសកាលបរិច្ឆេទប្រជុំ (៤៩%) មិនមានចំណាប់អារម្មណ៍នឹងកិច្ចប្រជុំ (២២%) និងរវល់/គ្មានពេល (២១%)។

ទោះជាយ៉ាងណា ភាគច្រើននៃតំណាងក្រុង ស្រុក (៧១%) បានអះអាងថារដ្ឋបាលរបស់ខ្លួនពិតជាបានបិទផ្សាយប្រតិទិននៃកិច្ចប្រជុំប្រឹក្សាសាមញ្ញ។ ប្រតិទិនត្រូវបានបិទលើក្តារផ្សព្វផ្សាយព័ត៌មាននៅឯការិយាល័យក្រុង ស្រុក ប៉ុន្តែក៏មានប្រើប្រាស់រួមគ្នាជាមួយមេឃុំ និងបិទនៅឯសាលាឃុំផងដែរ។ ដូច្នេះ មូលហេតុព័ត៌មានមិនអាចជ្រួតជ្រាបទៅដល់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ទំនងចេញពីអង្គហេតុដែលថាប្រជាពលរដ្ឋកម្រអញ្ជើញមកការិយាល័យរដ្ឋបាល និងមិនកត់សម្គាល់លើព័ត៌មានបែបនេះ។ ស្រុកកំរៀង បានអនុវត្តកិច្ចផ្តួចផ្តើមដើម្បីជំនះបញ្ហានេះ ហើយបច្ចុប្បន្នកំពុងប្រើប្រាស់កម្មវិធីតេឡេក្រាម (Telegram) ដើម្បីផ្សព្វផ្សាយរបៀបវារៈអង្គប្រជុំក្នុងចំណោមតំណាងប្រជាពលរដ្ឋ, មេឃុំ និងនាយប៉ុស្តិ៍នគរបាល។ នៅខេត្តបាត់ដំបង សេចក្តីប្រកាសអំពីកិច្ចប្រជុំក៏ធ្វើឡើង តាមរយៈហ្វេសប៊ុក និងតេឡេក្រាមផងដែរ។

ដើម្បីបង្កើនការចូលរួម រដ្ឋបាលស្រុកបាណន់បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានមួយចំនួនអំពីថវិកា និងគម្រោងថ្មីៗក្នុងទីសាធារណៈដូចជា ក្នុងវត្តបាណន់ និងនៅក្នុងសាលាភ្នំសំពៅផងដែរ។ នៅក្នុងដំណាក់កាលកន្លងមកនៃការអនុវត្ត I-SAF គ.ជ.អ.ប មានគម្រោងធ្វើការជាមួយក្រុងប៉ៃលិនដើម្បីលើកទឹកចិត្តការចូលរួមពីសាធារណជន ប៉ុន្តែបច្ចុប្បន្នដោយពុំមានការគាំទ្រពី គ.ជ.អ.ប រដ្ឋបាលមិនមានជំនាញដើម្បីធ្វើការជាមួយប្រជាពលរដ្ឋ និងទាក់ទាញចំណាប់អារម្មណ៍ពួកគាត់បានយ៉ាងមានប្រសិទ្ធភាពនោះឡើយ។

មានការយល់ស្របជាទូទៅក្នុងចំណោមមន្ត្រីក្រុង ស្រុកថា ការចូលរួមមានអត្រាទាបក្នុងកិច្ចប្រជុំគឺអាចពន្យល់បានពីកង្វះចំណាប់អារម្មណ៍។ ប្រជាពលរដ្ឋទំនងជាយល់ឃើញថា ថវិកាក្រុង ស្រុកគឺជាអ្វីមួយដែលជាផ្ទៃក្នុងរបស់រដ្ឋបាល ដូច្នេះហើយ ពុំមានចំណាប់អារម្មណ៍ក្នុងការដឹងពីថវិកា ឬពុំមានចំណាប់អារម្មណ៍យល់ដឹងអំពីដំណើរការរៀបចំថវិកាឡើយ។ ដរាបណា ប្រជាពលរដ្ឋមានចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ឬអាជីពទៅលើគម្រោងមួយ ឬសេចក្តីត្រូវការដោះស្រាយបញ្ហាណាមួយ ទើបគាត់សំដែងចំណាប់អារម្មណ៍ចូលរួមច្រើន។

## បញ្ហាទី ៧៖ ប្រជាពលរដ្ឋកម្រផ្តល់យោបល់ត្រលប់ទៅកាន់រដ្ឋបាលក្រុង ស្រុក

ដូចមន្ត្រីក្រុង ស្រុកមានប្រសាសន៍ *ការមានវត្តមាន* និង *ការចូលរួម* គឺជារឿងពីរផ្សេងគ្នា។ យោងតាមទាំងប្រជាពលរដ្ឋ និងសមាជិកក្រុមប្រឹក្សា ប្រជាពលរដ្ឋពីរបីនាក់ដែលចូលរួមមានវត្តមាន ទំនងជាមានតួនាទីអសកម្មក្នុងអំឡុងពេលពិភាក្សាគ្នា។ ពួកគាត់ជាធម្មតាចូលមានវត្តមានដើម្បីស្តាប់ ហើយភាគច្រើនសួរសំណួរពីរបីអំពីគម្រោងជាក់លាក់ណាមួយដែលកំពុងអនុវត្ត (ដូចជាការសាងសង់ផ្លូវថ្នល់ និងកសិកម្ម)។ មានប្រជាពលរដ្ឋតែ ១៣ នាក់ប៉ុណ្ណោះដែលបានរាយការណ៍ថា ធ្លាប់ផ្តល់ជាធាតុចូលក្នុងអំឡុងពេលប្រជុំក្រុមប្រឹក្សា ទោះបីជាក្នុងករណីភាគច្រើនគេផ្តល់ឱកាសឱ្យគាត់ធ្វើដូច្នោះក៏ដោយ។ ប្រជាពលរដ្ឋភាគច្រើនក៏បាននិយាយថា ក្រុមប្រឹក្សាពិចារណាធាតុចូលរបស់ខ្លួន លើកលែងតែអ្នកផ្តល់សម្ភាសន៍ម្នាក់ក្នុងខេត្តបាត់ដំបង និងម្នាក់ទៀតក្នុងខេត្តពោធិ៍សាត់។

មានភាពខុសគ្នាច្រើនទៅលើកម្រិតនៃការចូលរួមរបស់ប្រជាពលរដ្ឋ។ តំណាងប្រជាពលរដ្ឋ និងថ្នាក់ដឹកនាំសហគមន៍មានភាពសកម្មបំផុត ពីព្រោះពួកគាត់មានការប្តេជ្ញាចិត្តធ្វើជាតំណាងសហគមន៍របស់ពួកគាត់ ហើយពួកគាត់ជាអ្នកពាំនាំនូវក្តីបារម្ភ និងសេចក្តីត្រូវការរបស់សហគមន៍ពួកគាត់។ ម៉្យាងទៀត ទោះស្ត្រី និងជនចាស់ជរាគឺជាក្រុមពីរដែលជាធម្មតាបានចូលមានវត្តមានក្នុងកិច្ចប្រជុំ ពួកគាត់កម្រនឹងនិយាយ ឬលើកជាសំណូមពរទៅកាន់ក្រុមប្រឹក្សាណាស់។ ក្រៅពីកិច្ចប្រជុំ ប្រជាពលរដ្ឋក៏អាចស្នើសុំព័ត៌មាន ដាក់ពាក្យបណ្តឹង និងលើកសំណូមពររបស់ខ្លួនទៅកាន់រដ្ឋបាលក្រុង ស្រុក និងការិយាល័យប្រជាពលរដ្ឋដោយផ្ទាល់ និងតាមរយៈទូរស័ព្ទ លិខិត និងអ៊ីម៉ែល។

ទោះជាយ៉ាងនេះក្តី មន្ត្រី និងក្រុមប្រឹក្សាដែលផ្តល់សម្ភាសន៍តែ ២០% ប៉ុណ្ណោះដែលបានដឹងថាប្រជាពលរដ្ឋអាចមករដ្ឋបាលក្រុង ស្រុកសាកសួរ និងបញ្ចេញមតិយោបល់អំពីសេចក្តីព្រាងថវិកាប្រចាំឆ្នាំ (សូមមើលរូបភាព ៦.៦ សម្រាប់ព័ត៌មានលម្អិតបន្ថែម)។ នៅពេលប្រជាពលរដ្ឋធ្វើដូច្នោះ ជាធម្មតា គឺដោយសារពួកគាត់ចាប់អារម្មណ៍នឹងការវិភាជន៍ថវិកាសម្រាប់គម្រោងផ្សេងៗដែលប៉ះពាល់គាត់ដោយផ្ទាល់ ដូចជាគម្រោងសាងសង់ផ្លូវថ្នល់ អណ្តូងទឹក ស្រះ និងប្រឡាយ។

*រូបភាព ៦.៦៖ សំណួរសួរទៅកាន់រដ្ឋបាលក្រុង ស្រុក៖ តើប្រជាពលរដ្ឋធ្លាប់បានលើកគំនិត និងសំណូមពររបស់ខ្លួនអំពីសេចក្តីព្រាងថវិកាប្រចាំឆ្នាំដល់រដ្ឋបាលក្រុង ស្រុកលោកអ្នកដែរឬទេ? (n=69)*

| | ធ្លាប់ | មិនធ្លាប់ | មិនដឹង/គ្មានចម្លើយ |
|---|---|---|---|
| បាត់ដំបង | 21% | 70% | 9% |
| ប៉ៃលិន | 8% | 85% | 8% |
| ពោធិ៍សាត់ | 33% | 67% | 0% |

## 7. ការរកឃើញស្តីពីការបណ្តុះបណ្តាល និងការកសាងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុក

អ្នកផ្តល់សម្ភាសន៍នៅរដ្ឋបាលក្រុង ស្រុកបានរាយការណ៍ថា ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រធានបទផ្សេងៗជាច្រើនទៅតាមតំណែងរបស់ខ្លួន។ មានប្រធានបទបណ្តុះបណ្តាលពីរដែលដូចៗគ្នាក្នុងចំណោមពួកគាត់ នោះគឺគណនេយ្យភាពសង្គម និងភារកិច្ច និងការទទួលខុសត្រូវនៃមុខងារនីមួយៗនៅក្នុងរដ្ឋបាលក្រុង ស្រុក។ ខាងក្រោមនេះ គឺជាបញ្ជីវគ្គបណ្តុះបណ្តាលដែលប្រធានរដ្ឋបាល/ហិរញ្ញវត្ថុ ក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា និងអភិបាលរងបានទទួល។

*រូបភាព ៧.១៖ តារាងសង្ខេបប្រធានបទបណ្តុះបណ្តាលដែលបានទទួលទៅតាមមុខតំណែង*

| | |
|---|---|
| <u>ប្រធានរដ្ឋបាល/ហិរញ្ញវត្ថុ</u><br>- លិខិតកំណើត<br>- តួនាទី និងភារកិច្ចរបស់មន្ត្រីរាជការ<br>- ការគ្រប់គ្រងរដ្ឋបាល<br>- កម្មវិធី MS Office<br>- គណនេយ្យភាពសង្គម<br>- ការរៀបចំថវិកាប្រចាំឆ្នាំ (MEF) | <u>ប្រធានក្រុមប្រឹក្សា</u><br>- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុង ស្រុក<br>- កិច្ចការហិរញ្ញវត្ថុ និងការគ្រប់គ្រងរដ្ឋបាល<br>- គណនេយ្យភាពសង្គម<br>- ការគ្រប់គ្រងប្រព័ន្ធព័ត៌មានក្រុង/ស្រុក<br>- ការផ្សព្វផ្សាយព័ត៌មាន<br>- ការទប់ស្កាត់គ្រឿងញៀន |
| <u>អភិបាលរងទទួលបន្ទុកហិរញ្ញវត្ថុក្រុង ស្រុក</u><br>- ការគ្រប់គ្រងថវិកាស្រុក<br>- I-SAF<br>- វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្ម<br>- តួនាទី និងភារកិច្ចនៃក្រុមប្រឹក្សា និងគណៈអភិបាល | <u>គណៈកម្មាធិការលទ្ធកម្ម</u><br>- នីតិវិធីរដ្ឋបាល<br>- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា<br>- ការទប់ស្កាត់ និងត្រៀមបង្ការគ្រោះមហន្តរាយ |

| | |
|---|---|
| - ការត្រៀមរៀបចំផែនការ<br>- កិច្ចការរដ្ឋបាល និងការអភិវឌ្ឍស្ថាប័ន<br>- ជំនាញប្រាស្រ័យទាក់ទង | - ការអភិវឌ្ឍផែនការក្រុង ស្រុក<br>- ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាស្ត្រី និងកុមារ<br>- ជំនាញបច្ចេកទេសស្តីពីកសិកម្ម ការដឹកជញ្ជូនសាធារណៈ បញ្ហាសង្គម និងការអប់រំ<br>- លទ្ធកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ<br>- គណនេយ្យភាពសង្គម<br>- បណ្តាញសង្គម |
| <u>គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស</u><br>- ហិរញ្ញវត្ថុ (ប្រភពចំណូល និងការចំណាយ)<br>- ការអភិវឌ្ឍផែនការ<br>- តួនាទី និងភារកិច្ចនៃក្រុមប្រឹក្សាក្រុងស្រុក<br>- កិច្ចការរដ្ឋបាល<br>- ការគ្រប់គ្រង និងការអនុវត្តថវិកា<br>- គណនេយ្យភាពសង្គម<br>- ការប្រាស្រ័យទាក់ទង<br>- ដំណើរការរៀបចំផែនការ<br>- ការអភិវឌ្ឍស្ថាប័ន<br>- ដំណើរសមាហរណកម្ម<br>- យុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានទៅប្រជាពលរដ្ឋ<br>- ការគ្រប់គ្រងកាកសំណល់ | <u>គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ</u><br>- យេនឌ័រ និងសីលធម៌<br>- ការជួញដូរមនុស្ស និងអំពើហិង្សា<br>- ការចំណាកស្រុកខុសច្បាប់<br>- ការប្រែប្រួលអាកាសធាតុ<br>- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាក្រុងស្រុក<br>- ការអនុវត្តថវិការបស់ គ.ក.ស.ក<br>- សេវាសង្គម និងការផ្តល់សេវាសាធារណៈ<br>- ការគ្រប់គ្រងហាិរញ្ញវត្ថុ និងថវិកា<br>- ការប្រាស្រ័យទាក់ទង និងរបៀបនិយាយជាសាធារណៈ<br>- ជំនាញកុំព្យូទ័រ<br>- ភាពជាអ្នកដឹកនាំ<br>- ការសរសេរសំណើ<br>- ការអភិវឌ្ឍផែនការសកម្មភាព<br>- ការអភិវឌ្ឍស្ថានប័ន (តួនាទី និងការទទួលខុសត្រូវរបស់អភិបាល បុគ្គលិក និងអ្នកពាក់ព័ន្ធ)<br>- អភិបាលកិច្ចល្អ<br>- សិទ្ធិក្នុងការទទួលបានព័ត៌មាន |

៨០% នៃអ្នកផ្តល់សម្ភាសន៍ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងបែបផែនផ្សេងៗគ្នា។ ប្រធានបទបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាក់លាក់ និងភាគរយនៃអ្នកផ្តល់សម្ភាសន៍ដែលធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលត្រូវបានបង្ហាញនៅក្នុងរូបភាពខាងក្រោម៖

*រូបភាព ៧.២៖ ភាគរយនៃមន្ត្រីក្រុង ស្រុកដែលធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (n=49, អនុញ្ញាតឱ្យមានចម្លើយច្រើន)*




សម្គាល់៖ វគ្គបណ្តុះបណ្តាលស្តីពី *វដ្តគ្រប់គ្រងថវិកា* រួមបញ្ចូលភាពមានថវិកា លទ្ធកម្ម ការជំរះបញ្ជី និងការទូទាត់។ វគ្គបណ្តុះបណ្តាលស្តីពី *វដ្តថវិកា* រួមបញ្ចូលការរៀបចំថវិកា ការអនុវត្តថវិកា និងការត្រួតពិនិត្យតាមដានថវិកា។

វគ្គបណ្តុះបណ្តាលសម្រាប់រដ្ឋបាលក្រុង ស្រុកត្រូវបានរៀបចំឡើង តាមរយៈយន្តការចំនួន ៤ យ៉ាងគឺ៖

- **ក្រសួងថ្នាក់ជាតិ**

  **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ដើរតួយ៉ាងសំខាន់ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។ សិក្ខាសាលាថ្នាក់ភូមិភាគផ្តល់ការបណ្តុះបណ្តាលស្តីពី PFM ទៅដល់ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានរតនាគារខេត្ត និងអភិបាលរងខេត្ត។ ចំណែក ប្រធានរដ្ឋបាលហិរញ្ញវត្ថុ និងមន្ត្រីក្រុង ស្រុកត្រូវបានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំស្តីពីការរៀបចំថវិកា ក៏ប៉ុន្តែក្រុមប្រឹក្សាក្រុង ស្រុកមិនត្រូវបានគេអញ្ជើញឡើយ។ ប្រធានបទបណ្តុះបណ្តាល

ផ្ដោតអារម្មណ៍ទៅលើសារាចរស្ដីពីការរៀបចំថវិកា ការប្រមូលចំណូល និងការអនុវត្តថវិកាក្រុង ស្រុក។ ក្រៅពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសហការជាមួយ**វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** នឹងរៀបចំផ្ដល់វគ្គបណ្ដុះបណ្ដាលស្ដីពីការពិនិត្យពិច័យថវិកាទៅដល់សមាជិកក្រុមប្រឹក្សាមួយចំនួនដែលនឹងត្រូវកំណត់ជ្រើសរើស ដែលនេះគឺជាផែនការដែលត្រូវអនុវត្តនាពេលខាងមុខ។

ការបណ្ដុះបណ្ដាលក្រុមប្រឹក្សាស្ដីពីតួនាទីរបស់ខ្លួន និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ក្រុង ខេត្ត ស្រុក និងខណ្ឌ ស្ថិតក្រោមដែនសមត្ថកិច្ចរបស់**ក្រសួងមហាផ្ទៃ**។ អ្នកផ្ដល់សម្ភាសន៍មកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានមានប្រសាសន៍ថា ក្នុងឆ្នាំ ២០២០ នេះ ក្រសួងមានផែនការបណ្ដុះបណ្ដាលក្រុមប្រឹក្សាស្ដីពីការរៀបចំថវិកា ការចំណាយ និងការកត់ត្រាចំណូល ការបិទបញ្ជី និងប្រធានបទដទៃទៀត។

**អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាន គ.ជ.អ.ប** បានគាំទ្រឱ្យមានវគ្គបណ្ដុះបណ្ដាលក្រុមប្រឹក្សាក្រុង ស្រុកស្ដីពីការយល់ដឹងលើហិរញ្ញវត្ថុ តាមរយៈការសម្របសម្រួលអនុវត្តកម្មវិធីបណ្ដុះបណ្ដាល ដែលរៀបចំឡើងដោយស្ថាប័ននានា ដូចជា អ៊ីយូដារ (EU DAR) ក្នុងឆ្នាំ ២០១៨ និង ២០១៩។

- **មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរតនាគារខេត្ត** ផ្ដល់ការគាំទ្រនិងយោបល់ដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំថវិកា និងក្នុងការធានាថាថវិកាអនុវត្តស្របទៅតាមសេចក្ដីណែនាំរបស់ថ្នាក់ជាតិ និងថ្នាក់ខេត្ត។ រដ្ឋបាលខេត្តក៏មានផ្ដល់ជាវគ្គបណ្ដុះបណ្ដាលខ្លះដែរដូចជា ការផ្ដល់សេវាសាធារណៈ និងការរៀបចំសកម្មភាពនានារបស់ គ.ក.ស.ក។ អភិបាលរងទទួលបន្ទុកហិរញ្ញវត្ថុក្រុង ស្រុកនៅខេត្តបាត់ដំបងបានពន្យល់ថា រៀងរាល់ឆ្នាំការិយាល័យទាំងអស់របស់គាត់ទទួលបានការបណ្ដុះបណ្ដាលដើម្បីឱ្យយល់ដឹងអំពីថវិកា និងការចំណាយ។ ទោះជាយ៉ាងណា នៅពេលដែលពួកគេចង់បានវគ្គបច្ចេកទេសជាក់លាក់ណាមួយ ពួកគេនឹងទៅរកការិយាល័យខេត្ត។
- អ្នកផ្ដល់សម្ភាសន៍សង្កត់ធ្ងន់លើសារៈសំខាន់នៃ**វគ្គចែករំលែកចំណេះដឹងផ្ទៃក្នុង**ជាមួយរដ្ឋបាលក្រុង ស្រុក។ ក្រុមប្រឹក្សា និងមន្ត្រីក្រុង ស្រុកផ្លាស់វេនគ្នាដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួនទៅតាមមុខជំនាញរៀងៗខ្លួន។
- យោងតាមអ្នកផ្ដល់សម្ភាសន៍ភាគច្រើន **អង្គការសង្គមស៊ីវិល** បានផ្ដល់វគ្គបណ្ដុះបណ្ដាលដល់មន្ត្រី និងក្រុមប្រឹក្សារបស់ខ្លួន។ តួលេខនេះគឺស្មើ ១០០% ក្នុងចំណោមអ្នកផ្ដល់សម្ភាសន៍ទាំង

អស់ក្នុងនៅបាត់ដំបង មោងឫស្សី និងថ្មគោល។ អង្គការមិនមែនរដ្ឋាភិបាលដែលបានលើកឡើងដោយអ្នកផ្តល់សម្ភាសន៍ រួមមាន៖

- បាត់ដំបង៖ GIZ (DAR), អមរា, បន្ទាយស្រី, ទំនុកចិត្តកុមារកម្ពុជា (CCT)
- បាណន់៖ GIZ (DAR)
- បវេល៖ GIZ (DAR)
- កំរៀង៖ GIZ (DAR), ជីវិតថ្លៃថ្នូរ, CFS, ពុទ្ធិសាសនាសម្រាប់ការអភិវឌ្ឍ
- មោងឫស្សី៖ GIZ (DAR), ទស្សនៈពិភពលោក។ លោកប្រធានរដ្ឋបាល/ហិរញ្ញវត្ថុបានពន្យល់ថាអង្គការ GIZ បានផ្តល់វគ្គបណ្តុះបណ្តាលអំពីកម្មវិធី advanced MS Excel និង MS Word ។
- ពោធិ៍សាត់៖ អ្នកផ្តល់សម្ភាសន៍មិនអាចនឹកឃើញថាអង្គការមួយណា ប៉ុន្តែបានពន្យល់ថាមានអង្គការមិនមែនរដ្ឋាភិបាលធ្លាប់មកបណ្តុះបណ្តាលពួកគាត់អំពីអភិបាលកិច្ចល្អ សិទ្ធិទទួលបានព័ត៌មាន តួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីរាជការ និងការបញ្ច្រាបយេនឌ័រ។
- រតនមណ្ឌល៖ GIZ (DAR)
- ថ្មគោល៖ GIZ (DAR), អមរា, បន្ទាយស្រី

សកម្មភាពបណ្តុះបណ្តាល និងកសាងសមត្ថភាពមានតម្លៃជាវិជ្ជមាន ពីព្រោះសកម្មភាពទាំងនោះបានជំរុញឱ្យអ្នកផ្តល់សម្ភាសន៍កែលម្អការយល់ដឹង និងលទ្ធផលការងារចំពោះភារកិច្ចរបស់ខ្លួន។ គ្រប់អ្នកផ្តល់សម្ភាសន៍ទាំងអស់បង្ហាញអំពីចំណាប់អារម្មណ៍ និងចេតនាក្នុងការចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗស្តីពីការគ្រប់គ្រងថវិកា។

*រូបភាព ៧.៣៖ មូលហេតុដែលអ្នកផ្តល់សម្ភាសន៍ចង់ទទួលបានវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងថវិកា (n=67, អនុញ្ញាតឱ្យឆ្លើយបានច្រើន)*




# 8. អនុសាសន៍

## 8.1. សម្ភារៈ ឬឯកសារផ្សព្វផ្សាយថ្មី និងយុទ្ធសាស្ត្រក្នុងការផ្សព្វផ្សាយ

លទ្ធផលនៃការអង្កេតជាមួយប្រជាពលរដ្ឋបានបង្ហាញថា ពួកគាត់ជ្រើសរើសសម្ភារៈ ឬឯកសារផ្សព្វផ្សាយជាឯកសារបោះពុម្ពជាងឯកសារអនឡាញ។ គេបានឱ្យប្រជាពលរដ្ឋបានស្នើសុំឱ្យជ្រើសរើសឯកសារអប់រំងាយបំផុតពីបញ្ជីមួយ ដើម្បីយល់ដឹងអំពីព័ត៌មានថវិកា។ ជាទូទៅ ខិតប័ណ្ណគឺជាជម្រើសដែលមនុស្សគ្រប់ក្រុមអាយុជ្រើសរើស រួមទាំងជនចាស់ជរាផង។ ប៉ុន្តែ ប្រជាពលរដ្ឋដែលមានវ័យចំណាស់បានបង្ហាញពីភាពពេញចិត្តខ្លាំងលើជម្រើសនេះជាងប្រជាពលរដ្ឋដែលមានវ័យក្មេង ក្នុងនោះប្រជាពលរដ្ឋដែលមានអាយុ ពី៤៨ ដល់ ៥៧ ឆ្នាំ មាន ៣៧% និងប្រជាពលរដ្ឋអាយុលើសពី ៥៨ ឆ្នាំ មាន៤០% បើប្រៀបធៀបទៅនឹងក្រុមអាយុ ១៨ ដល់ ២៧ ឆ្នាំ មាន៣៣% ក្រុមអាយុ២៨ ដល់ ៣៧ ឆ្នាំ មាន៣២% និង ក្រុមអាយុ ៣៨ ដល់ ៤៧ ឆ្នាំ មាន២៩% ។

ផ្ទុយទៅវិញ ការចូលចិត្តមាតិកាលើបណ្តាញសង្គមរបស់ក្រុមអាយុវ័យចំណាស់មានភាពតិចជាងប្រជាពលរដ្ឋដែលមានអាយុក្មេង។ មានតែ ៧% នៃក្រុមអាយុពី ៤៨ ដល់ ៥៧ ឆ្នាំ និងអាយុលើសពី ៥៨ ឆ្នាំប៉ុណ្ណោះ ដែលបានជ្រើសរើសបណ្តាញសង្គម ខណៈដែលតួលេខនេះឡើងទៅដល់ ១៨% សម្រាប់ប្រជាពលរដ្ឋដែលមានអាយុរវាង ២៨ ដល់ ៣៧ ឆ្នាំ និង ១៦% សម្រាប់ប្រជាពលរដ្ឋអាយុរវាង ៣៨ ដល់ ៤៧ ឆ្នាំ។ សម្រាប់ក្រុមអាយុទាបជាងគេ (១៨ ដល់ ២៧ ឆ្នាំ) មាន ១៤% ដែលបានជ្រើសរើសបណ្តាញសង្គមថាជាឯកសារស័ក្តិសម ដើម្បីយល់ដឹងអំពីព័ត៌មានថវិកា។ ទោះជាងយ៉ាងណាក៏

ដោយ សុក្រិតភាពនៃតួលេខនេះ គួរត្រូវបានពិចារណាដោយប្រុងប្រយ័ត្ន ពីព្រោះតួលេខនេះឆ្លុះបញ្ចាំងតែទស្សនៈយល់ឃើញរបស់អ្នកផ្ដល់សម្ភាសន៍តែ ២០ នាក់ប៉ុណ្ណោះ។

ដូច្នេះ ចំណាប់អារម្មណ៍ទាបទូទៅសម្រាប់បណ្ដាញសង្គមដែលបានឆ្លុះបញ្ចាំងនៅក្នុងការអង្កេតនេះ ត្រូវបានពន្យល់បានខ្លះ ដោយភាពជាតំណាងទាបរបស់យុវជន (តែ ៦% ប៉ុណ្ណោះនៃចំនួនសំណាកសរុប)។ ក្រៅពីនេះ អត្រាប្រើប្រាស់អ៊ីនធើណេត និងការប្រើប្រាស់បណ្ដាញសង្គមមានការកើនឡើង ដែលនេះគឺជានិន្នាការមួយដែលចាំបាច់ដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រផ្សព្វផ្សាយ និងប្រាស្រ័យទាក់ទងរបស់រដ្ឋបាលសាធារណៈ។ ទោះជារដ្ឋបាលមូលដ្ឋានដឹងអំពីសក្ដានុពលនៃអត្ថប្រយោជន៍នៃការផ្សព្វផ្សាយអនឡាញយ៉ាងណាក៏ដោយ ក៏សកម្មភាពអនឡាញរបស់ពួកគាត់នៅមានសភាពទាបខ្លាំងនៅឡើយ ដោយសារមានដែនកំណត់ចម្បងៗចំនួន ២ គឺកង្វះថវិកា និងសមត្ថភាពបច្ចេកទេសមិនគ្រប់គ្រាន់។

*រូបភាព ៨.១៖ ភាពងាយស្រួលនៃយន្តការក្នុងការទទួលបានព័ត៌មានថវិកា បើយោងតាមប្រជាពលរដ្ឋ (n=៣៤០, អនុញ្ញាតឱ្យជ្រើសរើសចម្លើយច្រើន)*




សម្គាល់៖ តួលេខនីមួយៗឆ្លុះបញ្ចាំងអំពីភាគរយនៃប្រជាពលរដ្ឋសរុបដែលបានជ្រើសរើសជម្រើសផ្ដល់ជូននីមួយៗ។

ទីផ្សារគឺជាទីសាធារណៈងាយស្រួលបំផុតក្នុងការដាក់ក្ដារព័ត៌មានបើយោងតាមប្រជាពលរដ្ឋចំនួន ៣២% បន្ទាប់មកតាមវត្តអារាម (៣១%) តាមសាលារៀន (១៩%) និងតាមមណ្ឌលសុខភាព (១០%)។ រដ្ឋបាលក្រុងស្រុកបានយល់ស្របតាមមតិរបស់ប្រជាពលរដ្ឋលើយន្តការដែលស័ក្តិសមបំផុតក្នុងការផ្សព្វផ្សាយព័ត៌មាននេះ។

វិទ្យុ និងទូរទស្សន៍ដែលត្រូវបានប្រើប្រាស់ផ្សព្វផ្សាយព័ត៌មានអំពីថវិការួមមាន៖

- វិទ្យុ៖ ចម្ការដែក (ស្រុកបវិល) ចម្ការចេក (បាត់ដំបង)។
- ទូរទស្សន៍៖ ទទក (បាត់ដំបង) បាយ័ន (កំរៀង) ស៊ី ធី អិន (កំរៀង)។

**<u>បង្កើន និងធ្វើពិពិធកម្មឯកសារបោះពុម្ពសម្រាប់អប់រំ (IEC material)</u>**

សម្ភារៈ ឬឯកសារផ្សព្វផ្សាយត្រូវបានប្រជាពលរដ្ឋភាគច្រើនចូលចិត្តអាន និងងាយស្រួលយល់ជាងទម្រង់ឌីជីថល។ ទោះជាប្រការនេះទំនងជាផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស ហើយដោយពិចារណាថាតួលេខទាំងនេះតំណាងឱ្យភាគរយនៃប្រជាពលរដ្ឋមួយក្រុមតូច និងជាក់លាក់ ធៀបទៅនឹងប្រជាពលរដ្ឋសរុបក៏ដោយ ក៏ប្រជាពលរដ្ឋនៅក្នុងតំបន់សិក្សានេះភាគច្រើនយល់ថាឯកសារបោះពុម្ពងាយស្រួលទទួលបាន និងងាយស្រួលយល់ជាង។

វាមានសារៈសំខាន់ណាស់ក្នុងការបង្កើនបរិមាណឯកសារអប់រំសម្រាប់ប្រជាពលរដ្ឋ។ ឯកសារដែលនឹងត្រូវផលិត គួរមានភាពច្បាស់លាស់ ត្រឹមត្រូវ និងរួមមានរូបភាពដើម្បីទាក់ទាញការចាប់អារម្មណ៍របស់សាធារណជន។ ក្រៅពីនេះ អត្ថបទគួរខ្លីៗ និងសរសេរអក្សរទំហំធំ។ រូបភាពខាងក្រោមបង្ហាញអំពីតារាងដែលអ្នកផ្ដល់សម្ភាសន៍បានផ្ដល់ជូននៅក្នុងសិក្ខាសាលាពិគ្រោះយោបល់នៅភ្នំពេញ។

*រូបភាព ៨.២៖ តារាងដែលព្រាងឡើងនៅក្នុងសិក្ខាសាលានៅភ្នំពេញ ដើម្បីបង្ហាញពីព័ត៌មានថវិកាក្រុង ស្រុកទៅប្រជាពលរដ្ឋ*




មានសំណូមពរឱ្យប្តូរពាក្យ *ថវិកា* ទៅជា *កញ្ចប់លុយ* ហើយដាក់បញ្ចូលតែព័ត៌មានជាក់លាក់តែប៉ុណ្ណោះដែលសំខាន់សម្រាប់ប្រជាពលរដ្ឋ។ ព័ត៌មានស្តីពីចំណូល គួរមានតួលេខសរុប ប៉ុន្តែក៏បែងចែកចំណូលទៅតាមប្រភព ដូចជាចំណែកមកពីថ្នាក់ជាតិ និងថ្នាក់ខេត្ត ក៏ដូចជាចំនួនដែលប្រមូលបានដោយក្រុង ស្រុកខ្លួនឯង។ ការចំណាយគួរបញ្ចូលតួលេខសរុបជាមួយនឹងព័ត៌មានលម្អិតអំពីលុយដែលបានចាយលើរដ្ឋបាល ប្រាក់ខែបុគ្គលិក ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍរដ្ឋបាលក្រុង ស្រុក។

មតិយោបល់ និងការចង់បានដែលប្រមូលបានក្នុងអំឡុងពេលធ្វើការអង្កេតប្រជាពលរដ្ឋ កិច្ចសម្ភាសន៍ និងកិច្ចពិភាក្សាក្រុមគោលដៅបានឱ្យយើងរៀបចំជាអនុសាសន៍មួយចំនួនសម្រាប់ឯកសារបោះពុម្ពសម្រាប់អប់រំ៖

- រូបភាពព័ត៌មានដែលបានស្នើឡើង៖ ផលិតរូបភាពព័ត៌មានដើម្បីបង្ហាញអំពីប្រភពសំខាន់ៗនៃចំណូល និងចំណាយក្នុងទម្រង់មួយងាយស្រួល។ រូបភាពព័ត៌មាននៅក្នុងឧបសម្ព័ន្ធទី ៣ គឺជាឧទាហរណ៍នៃថវិកាមួយនៅស្រុកអូជ្រៅ ខេត្តបន្ទាយមានជ័យ ហើយអាចត្រូវបានយកទៅកែសម្រួលទៅតាមថវិការបស់រដ្ឋបាលក្រុង ស្រុកដទៃទៀត។

- ផ្ទាំងរូបភាពដែលមានរូបពណ៌ផ្សេងៗ និងមានសារច្បាស់លាស់ និងត្រឹមត្រូវ។ ឧទាហរណ៍ តារាងមួយដែលបង្ហាញការចំណាយថវិកាក្រុង ស្រុកសំខាន់ៗទៅតាមគម្រោង ឬសកម្មភាព។ ឧបសម្ព័ន្ធទី ៤ មានឧទាហរណ៍មួយនៃផ្ទាំងរូបភាពងាយស្រួលយល់ដែលគេប្រទះឃើញនៅលើក្តារព័ត៌មាននៅឯការិយាល័យស្រុកមោងឫស្សី ដែលពន្យល់អំពីជំហានផ្សេងៗដែលប្រជាពលរដ្ឋត្រូវអនុវត្តតាមក្នុងពេលបោះឆ្នោត។
- ផ្ទាំងរូបភាពទៅតាមប្រធានបទ ដើម្បីជម្រាបប្រជាពលរដ្ឋអំពីសារៈសំខាន់នៃថវិកាក្រុង ស្រុក សម្រាប់សេវាផ្សេងៗដែលពួកគាត់ប្រើ។ ឧទាហរណ៍ ផ្ទាំងរូបភាពដែលបង្ហាញការចំណាយថែទាំសុខភាពដែលបានបិទក្នុងមណ្ឌលសុខភាព នឹងអាចទាញការចាប់អារម្មណ៍ប្រជាជនឱ្យមកប្រើសេវាបែបនេះ។
- ខិតប័ណ្ណផ្តល់នូវ i) សេចក្តីសង្ខេបនៃខ្លឹមសារថវិកាក្រុង ស្រុកប្រចាំឆ្នាំ (ចំណូល និងចំណាយ) ii) ព័ត៌មានអំពីកិច្ចប្រជុំនានាដែលប្រជាពលរដ្ឋអាចចូលរួមដើម្បីជ្រាបជាព័ត៌មាន និងតាមដានការអនុវត្តគម្រោង iii) ការត្រួតពិនិត្យឡើងវិញនៃយន្តការនានាដែលតាមរយៈយន្តការទាំងនោះ ប្រជាពលរដ្ឋអាចមានលទ្ធភាពទទួលបានព័ត៌មាន និងលើកជាសំណួរ និងក្តីបារម្ភទៅកាន់រដ្ឋបាល។ ខិតប័ណ្ណគួរមាននៅការិយាល័យក្រុង ស្រុក និងទីសាធារណៈផ្សេងៗដូចជាសាលារៀន និងវត្តអារាម និងមានការចែកនូវវេទិកាសាធារណៈនានាផងដែរ។
- ឯកសារជាក់ស្តែងដែលប្រជាពលរដ្ឋប្រើប្រាស់ជាញឹកញាប់ដូចជាប្រតិទិន ឆ័ត្រ និងកាបូបដែលបង្ហាញពីសារចំៗអំពីថវិកាក្រុង ស្រុក។
- សារដែលត្រូវបានគេថតទុកជាស្រេច ដើម្បីចាក់ឧគ្ឃោសនាស័ព្ទក្នុងទីសាធារណៈ។ ឃ្លោសនាស័ព្ទចល័ត និងបង្ហាញជាវីដេអូស័ក្តិសមដើម្បីធ្វើឱ្យតំបន់ដាច់ស្រយាលបំផុតជ្រួតជ្រាបព័ត៌មាន។

**<u>ធ្វើការងារជាមួយអង្គការសង្គមស៊ីវិលក្នុងការផលិត និងការផ្សព្វផ្សាយឯកសារអប់រំ</u>**

វត្តមាននៃឯកសារអប់រំអំពីថវិកាក្រុង ស្រុកប្រចាំឆ្នាំ បច្ចុប្បន្នមានតិចតួច ឬមិនមានតែម្តង។ ដូចបានលើកឡើងក្នុងវគ្គមុន អង្គការសង្គមស៊ីវិលបាននឹងកំពុងធ្វើការយ៉ាងជិតស្និទជាមួយរដ្ឋបាលឃុំសង្កាត់ក្នុងការផលិត និងផ្សព្វផ្សាយថវិការបស់ខ្លួន។ ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលក្នុងការអនុវត្ត I-SAF និងតួនាទីរបស់ខ្លួនក្នុងការកសាងសមត្ថភាព និងផលិតឯកសារព័ត៌មានត្រូវបានរដ្ឋបាលក្រុង ស្រុកយល់ឃើញថាវិជ្ជមាន នេះក៏ដូចជាការយល់ឃើញរបស់ក្រសួងថ្នាក់ជាតិដែរ។ ជា

ឧទាហរណ៍ ឧបសម្ព័ន្ធទី ៥ បង្ហាញអំពីថវិកាស្រុកបាកាន ដែលបានរៀបចំឡើងដោយមានការគាំទ្រពីវិទ្យាស្ថាន API ។

អង្គការសង្គមស៊ីវិលមានទំនាក់ទំនងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ និងយល់ដឹងពីសេចក្តីត្រូវការ ក្តីបារម្ភ និងចំណូលចិត្តរបស់ប្រជាពលរដ្ឋមុនគេ។ ដូច្នេះ អង្គការសង្គមស៊ីវិលអាចជាតំណភ្ជាប់ដ៏មានប្រសិទ្ធភាពរវាងរដ្ឋបាល និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយដើរតួយ៉ាងសំខាន់ក្នុងការផលិតឯកសារអប់រំងាយស្រួលយល់ ក៏ដូចជាចុះជួបសហគមន៍ ផ្សព្វផ្សាយព័ត៌មាន និងលើកកម្ពស់ការយល់ដឹង។ សេចក្តីត្រូវការក្នុងការបង្កើនកិច្ចសហការជាមួយអ្នកពាក់ព័ន្ធក្នុងការផលិត និងផ្សព្វផ្សាយព័ត៌មានថវិកាក្រុង ស្រុក ត្រូវបានលើកឡើងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយជាមួយនឹងសំណើឱ្យអង្គការសង្គមស៊ីវិលជួយគាំទ្រកិច្ចប្រជុំប្រចាំខែរបស់ក្រុង ស្រុក។

<u>**ដាក់ក្តារព័ត៌មានក្នុងទីសាធារណៈ**</u>

ដោយសារប្រជាពលរដ្ឋកម្រអញ្ជើញមកការិយាល័យស្រុក/ឃុំ ប្រជាពលរដ្ឋភាគច្រើនព្រងើយកន្តើយនឹងការផ្សព្វផ្សាយព័ត៌មានផ្សេងៗ ដែលបានបិទផ្សាយនៅលើក្តារព័ត៌មានសាធារណៈនៅការិយាល័យក្រុង ស្រុក។ ព័ត៌មានគួរត្រូវបានដាក់ក្នុងទីសាធារណៈ ដែលប្រជាពលរដ្ឋនិយមជួបជុំ។ យោងតាមប្រជាពលរដ្ឋក៏ដូចជាតំណាងមន្ត្រីក្រុង ស្រុក ទីតាំងដែលងាយស្រួលបំផុតមានដូចជាទីផ្សារ វត្តអារាម សាលារៀន និងកន្លែងមួយចំនួនទៀតដូចជាមណ្ឌលសុខភាព។ ប្រការនេះអាចជំរុញឱ្យប្រជាពលរដ្ឋទទួលបានព័ត៌មានក្នុងពេលធ្វើការងារប្រចាំថ្ងៃរបស់ខ្លួន ហើយក៏មិនចាំបាច់ត្រូវការធ្វើដំណើរឆ្ងាយឡើយ។ ក្រៅពីនេះ ក្តារព័ត៌មានសាធារណៈជាចំណាយតិចតួចចំពោះរដ្ឋបាល ប៉ុន្តែការដាក់ក្តារព័ត៌មានសាធារណៈនៅទីតាំងខាងលើផ្តល់សក្តានុពលខ្ពស់សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈរួមទាំងស្ត្រី និងបុរស និងក្រុមអាយុផ្សេងៗគ្នាទទួលបានព័ត៌មាន។

<u>**មាតិកាឌីជីថលកាន់តែច្រើន ដើម្បីបង្កើនការចូលរួម និងទំនាក់ទំនងជាសាធារណៈជាមួយប្រជាពលរដ្ឋ**</u>

ការផលិតឯកសារបោះពុម្ពគួរដើរទន្ទឹមគ្នាជាមួយការបង្កើនវត្តមានអនឡាញរបស់រដ្ឋបាល។ មាតិកាឌីជីថលព័ត៌មានស្អាតៗទាក់ភ្នែក ងាយស្រួលទាក់ទាញការចាប់អារម្មណ៍របស់ទស្សនិកជន។ មាតិកាឌីជីថលមានភាពទាក់ទាញអតិថិជនគ្រប់ស្រទាប់ និងអាចចែកចាយបានយ៉ាងឆាប់រហ័ស។ ក្រៅពីនេះ ខ្លឹមសារឌីជីថលទំនងជាប្រើប្រាស់ពេលវេលាតិចជាង និងតម្រូវការធនធានសេដ្ឋកិច្ចតិចជាងឯកសារបោះពុម្ព។

បច្ចុប្បន្ននេះ រដ្ឋបាលក្រុង ស្រុកពុំមានសមត្ថភាពបង្កើតគេហទំព័រផ្លូវការ ហើយទោះបីពួកគាត់អាចបង្កើតគណនីបណ្តាញសង្គមយ៉ាងណាក៏ដោយ ក៏សកម្មភាពអនឡាញរបស់គាត់នៅមានសភាពទាបល្មមដែរ។ ការផ្សព្វផ្សាយអនឡាញគួរផ្តោត ជាពិសេសលើយុវជន ប្រជាពលរដ្ឋវ័យកណ្តាល និងស្ត្រីដែលបង្ហាញចំណាប់អារម្មណ៍លើទម្រង់ឌីជីថលបែបនេះខ្ពស់។ អ្វីដែលគួរឱ្យកត់សម្គាល់ផងនោះគឺថាជិតពាក់កណ្តាលនៃប្រជាពលរដ្ឋដែលផ្តល់សម្ភាសន៍មិនមានទូរស័ព្ទដៃទំនើប (smartphone) ភ្ជាប់អ៊ីនធើណេតឡើយ ខណៈដែល ៥% ក្នុងចំណោមនោះបានប្រើប្រាស់ទូរស័ព្ទរបស់អ្នកដទៃផ្សេងទៀត ប៉ុន្តែតួលេខទាំងនេះមានការប្រែប្រួលខ្លាំង។

ហ្វេសប៊ុក គឺជាវេទិកាបណ្តាញសង្គមដែលមានប្រជាប្រិយភាពបំផុតនៅកម្ពុជា ដូច្នេះហើយហ្វេសប៊ុកគឺជាបណ្តាញមួយដែលត្រូវផ្តល់អាទិភាពខ្ពស់។ វាជំរុញឱ្យមានការបង្កើត និងចែករំលែកខ្លឹមសារដែលអាចផលិតបានយ៉ាងឆាប់រហ័ស និងថាមវន្ត ការប្រកាសព័ត៌មាន និងដំណឹងថ្មីៗ ព័ត៌មានតាមរយៈរូបភាព និងវីដេអូផ្សេងៗ។ ក្រៅពីនេះ ក្រុមនានានៅក្នុងហ្វេសប៊ុកអាចសម្របសម្រួលឱ្យមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ច្រើនជាមួយក្រុមពាក់ព័ន្ធនានា និងប្រជាពលរដ្ឋ។

រដ្ឋបាលក្រុង ស្រុកគួរតែចេះទាញប្រយោជន៍ឱ្យបានទ្វេដងពីការប្រើប្រាស់ប្រព័ន្ធអនឡាញ។ ឧបករណ៍អនឡាញមិនមែនគ្រាន់តែជាមធ្យោបាយមួយសម្រាប់រដ្ឋបាលក្នុងការចែករំលែកព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាឱកាសមួយឱ្យប្រជាពលរដ្ឋផ្តល់ប្រតិកម្មទៅនឹងព័ត៌មាន និងផ្តល់មតិយោបល់របស់ខ្លួនតាមរយៈក្រុមហ្វេសប៊ុក សារហ្វេសប៊ុកទៅលើព័ត៌មានដែលបានផ្សព្វផ្សាយទាំងនោះផងដែរ។

## ការអប់រំ និងការធ្វើការជាមួយយុវជន

យុវជនជំនាន់ក្រោយដើរតួយ៉ាងសំខាន់ក្នុងការជុសខាត់អនាគត និងកសាងសង្គម តាមរយៈការចូលរួមក្នុងកិច្ចការសាធារណៈ និងការអភិវឌ្ឍសហគមន៍របស់ខ្លួន។ ចំណែក សាលារៀនគួរតែដើរតួនាទីជាអ្នកដឹកនាំក្នុងការផ្តល់នូវចំណេះដឹងផ្នែកហិរញ្ញវត្ថុដល់សិស្សានុសិស្ស។ ដើម្បីធានាអំពីនិរន្តរភាព និងរក្សានូវកិច្ចផ្តួចផ្តើមនេះឱ្យមានស្តង់ការតែមួយដូចគ្នា ក្រសួងអប់រំ យុវជន និងកីឡាគួរពិចារណាដាក់បញ្ចូលការអប់រំការយល់ដឹងផ្នែកហិរញ្ញវត្ថុក្នុងកម្មវិធីសិក្សា។ ការបណ្តុះសមត្ថភាព និងចំណង់ចំណូលចិត្តរបស់យុវជនលើកិច្ចការងារទាក់ទងនឹងថវិកា និងកិច្ចការសាធារណៈ អាចនឹងជំរុញឱ្យពួកគាត់មានការចូលរួមយ៉ាងសកម្មលើកិច្ចការនេះនាពេលអនាគតខាងមុខ។ ក្រៅពីនេះ អង្គការយុវជននានាអាចជាអ្នកពាក់ព័ន្ធមួយយ៉ាងសំខាន់សម្រាប់អាជ្ញាធរមូលដ្ឋានក្នុងការគៀរគរយុវជននិងបង្កើនការចូលរួមរបស់ពួកគាត់ក្នុងកិច្ចការសាធារណៈ។

យោងតាមការលើកឡើងដោយអង្គការសង្គមស៊ីវិលមួយចំនួន ការមិនបានផ្តល់ពេលវេលាគ្រប់គ្រាន់បានរារាំងយុវជនពីការចូលរួមក្នុងកិច្ចការសាធារណៈ ទោះជាពួកគាត់មានថាមពល និងការតាំងចិត្តធ្វើយ៉ាងណាក៏ដោយ។ ដូច្នេះ វេទិកាអនឡាញ គឺជាដំណោះស្រាយមួយយ៉ាងល្អ និងដោយផ្ទាល់ ដែលអាចទាក់ទងយុវជនជំនាន់ក្រោយបានយ៉ាងលឿន ពីព្រោះពួកគាត់មានភាពសកម្មបំផុតលើបណ្តាញសង្គម ជាពិសេសហ្វេសប៊ុក។ ចំណែក ក្រុមតេឡេក្រាមអាចប្រើប្រាស់បានចំពោះសិស្សនិស្សិតដែលជាមធ្យោបាយដ៏ស័ក្តិសមក្នុងការកសាងទំនាក់ទំនងដោយផ្ទាល់ជាមួយរដ្ឋបាលក្រុង ស្រុក។

## <u>ប្រើប្រាស់តេឡេក្រាមដើម្បីផ្តល់ព័ត៌មានដោយផ្ទាល់ និងភ្លាមៗដល់ប្រជាពលរដ្ឋតាមក្រុមផ្សេងៗគ្នា</u>

កម្មវិធីតេឡេក្រាម គឺជាឧបករណ៍ប្រាស្រ័យទាក់ទងដ៏ឆាប់រហ័ស និងឥតគិតថ្លៃ ដែលត្រូវបានបញ្ជាក់ប្រាប់ថាមានប្រសិទ្ធភាពសម្រាប់រដ្ឋបាលក្រុង ស្រុក។ តួយ៉ាង ស្រុកបរវេលបច្ចុប្បន្នបានកំពុងប្រើប្រាស់ក្រុមតេឡេក្រាម សម្រាប់ការប្រមែប្រមូលប្រជាពលរដ្ឋវ័យក្មេងចំនួន ១០០ នាក់ និងក្រុមដាច់ដោយឡែកមួយផ្សេងទៀត ដើម្បីប្រាស្រ័យទាក់ទងជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា។ ឧទាហរណ៍ល្អមួយទៀតត្រូវបានរកឃើញនៅស្រុកកំរៀង ដែលរដ្ឋបាលបានប្រើប្រាស់កម្មវិធីតេឡេក្រាមនេះ ដើម្បីផ្សព្វផ្សាយដំណឹង និងព័ត៌មានអំពីកិច្ចប្រជុំផ្សេងៗជាមួយអ្នកពាក់ព័ន្ធនានា។

កម្មវិធីតេឡេក្រាមផ្តល់នូវឧបករណ៍ចំនួន ២ ដែលងាយស្រួលក្នុងការអនុវត្ត និងអាចត្រូវបានគេប្រើប្រាស់បំពេញគ្នាទៅវិញទៅមក។ ឧបករណ៍ទី ១ កម្មវិធីតេឡេក្រាមមានប៉ុស្តិ៍ ដែលអាចផ្សព្វផ្សាយព័ត៌មានជាសាធារណៈបានទូលំទូលាយទៅកាន់មនុស្សម្នារាប់ពាន់នាក់។ ប៉ុស្តិ៍តេឡេក្រាម (Telegram channels) នេះមានមុខងារបើកមើល ដែលអនុញ្ញាតឱ្យយើងតាមដានសកម្មភាព និងមានអ្នកចូលជាសមាជិកគ្មានកំណត់។ ឧបករណ៍ទី ២ គឺក្រុមតេឡេក្រាម (Telegram groups) ដែលអនុញ្ញាតឱ្យសមាជិកក្រុមនេះប្រាស្រ័យទាក់ទង និងអាចឱ្យរដ្ឋបាល (admin) ចង្អុលបង្ហាញនូវសារសំខាន់ៗដែលធានាថាសារទាំងនោះត្រូវបានគេអានដូចជា សេចក្តីប្រកាសអំពីអង្គប្រជុំជាដើម។ បើផ្អែកតាមចំនួនប្រជាជនក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ការកំណត់សមាជិក ២០ ម៉ឺននាក់ក្នុងមួយក្រុម មិនមានជាបញ្ហាអ្វីឡើយសម្រាប់រដ្ឋបាលក្រុង ស្រុក ។

អ្វីដែលល្អ និងផ្អែកលើការចង់បាន និងសមត្ថភាពរបស់រដ្ឋបាលនីមួយៗក្នុងការគ្រប់គ្រងឧបករណ៍នេះ រដ្ឋបាលក្រុង ស្រុកអាចប្រើទាំងក្រុមតេឡេក្រាម និងប៉ុស្តិ៍តេឡេក្រាម។ រាល់ឯកសារទាំងអស់ និងបច្ចុប្បន្នភាពអាចចែករំលែកនៅក្នុងប៉ុស្តិ៍តេឡេក្រាម ដែលនៅក្នុងនោះប្រជាពលរដ្ឋអាចទទួលសេចក្តីជូនដំណឹង និងព័ត៌មានដោយផ្ទាល់ពីរដ្ឋបាល។ ទន្ទឹមគ្នានេះដែរ រដ្ឋបាលក្រុង ស្រុកអាច

បង្កើតក្រុមតេឡេក្រាមដាច់ដោយឡែកសម្រាប់ក្រុមប្រជាជនជាក់លាក់ដូចជា ក្រុមស្ត្រី យុវជន កសិករ ជាដើម ដើម្បីដោះស្រាយបញ្ហាសំខាន់ៗរបស់ពួកគាត់ ហើយក៏អាចកសាងទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ។

នៅតំបន់ដែលដាច់ស្រយាលខ្លាំង ឧគ្ឃោសនាសព្ទដាក់លើរថយន្ត ឬលើរម៉កកង់បីអាចជួយសម្របសម្រួលឱ្យព័ត៌មានជ្រាបដល់ប្រជាពលរដ្ឋដែលមិនមានអ៊ីនធើណេត។ រូបភាព និងគំនូរគឺជាឧបករណ៍ដ៏ល្អក្នុងការលើកកម្ពស់ការយល់ដឹងក្នុងចំណោមប្រជាពលរដ្ឋមិនចេះអក្សរ។ នៅក្នុងខេត្តប៉ៃលិន មានឧគ្ឃោសនាសព្ទដែលគេដំឡើងជាអចិន្ត្រៃយ៍អាចប្រើប្រាស់ដើម្បីផ្សព្វផ្សាយសារស្តីពីថវិកាប្រចាំឆ្នាំផងដែរ។

<u>**ការបណ្តុះបណ្តាលមន្ត្រីក្រុង ស្រុកអំពីជំនាញឌីជីថល**</u>

កង្វះជំនាញឌីជីថលរារាំងសមត្ថភាពរបស់រដ្ឋបាលក្រុង ស្រុកក្នុងការពង្រីកវត្តមានលើប្រព័ន្ធអនឡាញរបស់ខ្លួន។ គ្រប់រដ្ឋបាលក្រុង ស្រុកបានទទួលស្គាល់ថា កង្វះសមត្ថភាពបច្ចេកទេសគឺជាឧបសគ្គយ៉ាងសំខាន់មួយក្នុងការផលិតខ្លឹមសារឌីជីថល និងបង្កើនសកម្មភាពលើប្រព័ន្ធអនឡាញរបស់ខ្លួន។ រដ្ឋបាលនានាបានបង្ហាញចំណាប់អារម្មណ៍ក្នុងការចូលរួមក្នុងសកម្មភាពកសាងសមត្ថភាព និងរៀនផលិតខ្លឹមសារឌីជីថល និងគ្រប់គ្រងទំព័រហ្វេសប៊ុកក្រុង ស្រុក។ ប្រធានបទបណ្តុះបណ្តាលគួរផ្តោតលើការលើកកម្ពស់ជំនាញអនុវត្តបានភ្លាមៗ ដូចជារបៀបបង្កើតវីដេអូ និងគំនូរជីវចលខ្លីៗ រូបភាពព័ត៌មាន និងការគ្រប់គ្រងទំព័រហ្វេសប៊ុក (ការដាក់តាំងព័ត៌មាន ការតាមដានសកម្មភាពអ្នកប្រើប្រាស់ និងការលើកកម្ពស់ការចូលរួមយ៉ាងសកម្ម)។ ក្រៅពីនេះ រដ្ឋបាលមួយចំនួនបានសំដែងចំណាប់អារម្មណ៍របស់ខ្លួនក្នុងការថត និងចាក់ផ្សាយវីដេអូផ្ទាល់អំពីកិច្ចប្រជុំ ពីព្រោះចំណុចនេះ ពួកគាត់នៅខ្វះជំនាញផងដែរ។

### 8.2. ការជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋត្រូវមានភាពជាម្ចាស់ទៅលើថវិកាក្រុង ស្រុក ដើម្បីលុបបំបាត់នូវការយល់ឃើញជាទូទៅដែលថា ថវិកាគឺជារឿងផ្ទៃក្នុងរបស់រដ្ឋបាល ដែលមិនទុកឱកាសឱ្យប្រជាពលរដ្ឋអាចចូលរួមបាន។ ការផ្លាស់ប្តូរការយល់ឃើញទៅលើផលប៉ះពាល់ដោយផ្ទាល់ពីថវិកាចំពោះផលប្រយជន៍ផ្ទាល់ខ្លួន និងអាជីពរបស់ខ្លួនឯង ក៏ដូចជាទៅលើការអភិវឌ្ឍសហគមន៍របស់ខ្លួន គឺជាជំហានដំបូងក្នុងការបង្កើនចំណាប់អារម្មណ៍ និងឆន្ទៈរបស់សាធារណជនក្នុងការចូលរួម។

**<u>ជម្រាបប្រជាពលរដ្ឋអំពីប្រតិទិនប្រជុំរបស់ក្រុមប្រឹក្សា</u>**

រដ្ឋបាលក្រុង ស្រុកចាំបាច់ធានាថា ប្រជាពលរដ្ឋបានយល់ដឹងអំពីទីកន្លែង និងកាលបរិច្ឆេទកិច្ចប្រជុំរបស់ក្រុមប្រឹក្សាជាមុន ដោយសារតែការមិនដឹងកិច្ចប្រជុំរៀបចំនៅពេលណាគឺជាមូលហេតុសំខាន់បំផុតដែលបានរាយការណ៍ពីសំណាក់ប្រជាពលរដ្ឋដែលពុំធ្លាប់ចូលមាននៅក្នុងអង្គប្រជុំ។ ដូច្នេះ ទោះជាក្រុមប្រឹក្សាមិនមានកាតព្វកិច្ចផ្លូវច្បាប់ធ្វើដូច្នោះក៏ដោយ ក៏ពួកគាត់គួរចេញសេចក្តីជូនដំណឹងផ្សេងៗដល់សាធារណជនសម្រាប់រាល់កិច្ចប្រជុំ រួមទាំងរបៀបវារៈសង្ខេបផងដែរ។

ប្រតិទិន និងសេចក្តីជូនដំណឹងនៃអង្គប្រជុំគួរមានលើក្តារព័ត៌មានជាសាធារណៈនៅឯការិយាល័យក្រុង ស្រុក និងទីតាំងសាធារណៈនានាក៏ដូចជាក្នុងក្រុម និងប៉ុស្តិ៍តេឡេក្រាម។ ក្រៅពីនេះ ដោយសារការងាររបស់អង្គការសង្គមស៊ីវិលមូលដ្ឋាន មេភូមិ និងរដ្ឋបាលឃុំ សង្កាត់គឺធ្វើការផ្ទាល់ជាមួយប្រជាពលរដ្ឋ ដូច្នេះព័ត៌មានបែបនេះក៏អាចផ្សព្វផ្សាយតាមរយៈពួកគាត់បានដែរ។

**<u>ពង្រឹងកិច្ចសម្របសម្រួលរវាងអ្នកពាក់ព័ន្ធ</u>**

រដ្ឋបាលក្រុង ស្រុកចាំបាច់កសាងទំនាក់ទំនងឱ្យជិតស្និទ្ធជាងមុន និងដោយផ្ទាល់ជាងមុនជាមួយប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជំហានដំបូង គួរពង្រឹងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធ ៣ ប្រភេទដែលមានទំនាក់ទំនងល្អ និងការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ក្នុងនោះមានដូចជាអង្គការសង្គមស៊ីវិលធ្វើការនៅកម្រិតមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់ និងអ្នកដឹកនាំសហគមន៍ ដូចជាអ្នកតំណាងប្រជាពលរដ្ឋ និងមេភូមិ។ ពួកគាត់សុទ្ធតែអាចចូលរួមចំណែកក្នុងការកៀរគរប្រជាពលរដ្ឋដោយលើកកម្ពស់ការយល់ដឹង ជម្រាបអំពីកិច្ចប្រជុំ និងលើកទឹកចិត្តប្រជាពលរដ្ឋឱ្យបញ្ចេញយោបល់។ អ្នកផ្តល់សម្ភាសន៍មកពីរដ្ឋបាលក្រុង ស្រុកមានចំណាប់អារម្មណ៍ខ្លាំងចំពោះអង្គការសង្គមស៊ីវិល ដោយសារអង្គការទាំងនោះបានធ្វើការងារយ៉ាងច្រើនសន្ធឹកសន្ធាប់នៅថ្នាក់ឃុំ។

**<u>ជំរុញការចូលរួមតាមអនឡាញ</u>**

បណ្តាញអនឡាញ (online channels) គួរត្រូវបានប្រើប្រាស់ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។ វាអាចផ្តល់ឱ្យប្រជាពលរដ្ឋមានលទ្ធភាពចូលរួមពីទីកន្លែងណាក៏បានតាមរយៈទូរស័ព្ទចល័តរបស់ខ្លួន។ ឧបករណ៍ខាងក្រោមគឺងាយស្រួលក្នុងការប្រើប្រាស់ ប៉ុន្តែតម្រូវឱ្យរដ្ឋបាលត្រូវបង្កើតទំព័រហ្វេសប៊ុកមួយ។

- ផ្សព្វផ្សាយកិច្ចប្រជុំលើហ្វេសប៊ុក។ ប្រជាពលរដ្ឋអាចចូលមានក្នុងកិច្ចប្រជុំនានាតាមរយៈកុំព្យូទ័រយួរដៃ និងទូរស័ព្ទរបស់ខ្លួន និងអាចលើកជាសំណួរ និងមតិយោបល់របស់ខ្លួនដោយមានយោបល់លើវីដេអូ។ ចូរចំណាំថា កិច្ចផ្តួចផ្តើមនេះអាចតម្រូវឱ្យមានការអនុម័តជាផ្លូវការ។ ឧទាហរណ៍ រដ្ឋបាលស្រុកកំរៀង បានពិចារណាលទ្ធភាពរៀបចំកិច្ចប្រជុំ (ឡាយ) បន្តផ្ទាល់លើបណ្តាញហ្វេសប៊ុក ប៉ុន្តែបានមានប្រសាសន៍ថាត្រូវការការអនុម័តពីគណៈអភិបាលជាមុនសិន។
- វគ្គសំណួរចម្លើយបន្តផ្ទាល់លើហ្វេសប៊ុក។ ជាមធ្យោបាយមួយគួរឱ្យចាប់អារម្មណ៍សម្រាប់មន្ត្រី និងក្រុមប្រឹក្សាក្រុង ស្រុកដើម្បីធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់អំពីថវិកា និងចម្លើយទៅនឹងសំណួររបស់ប្រជាពលរដ្ឋផ្ញើមកភ្លាមៗ។
- លើកទឹកចិត្តសាធារណជនឱ្យផ្តល់យោបល់ត្រលប់តាមអនឡាញ។ នេះជាជម្រើសងាយស្រួល និងឆាប់រហ័សដែលអាចធ្វើឱ្យប្រជាពលរដ្ឋមានអារម្មណ៍ងាយស្រួលជាងការលើកជាសំណួររបស់ខ្លួនពេលមុខផ្ទាល់។

### 8.3. ការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលក្រុង ស្រុក

ឱកាសបណ្តុះបណ្តាលបន្ថែមគឺមានសារៈសំខាន់ណាស់ ដើម្បីដោះស្រាយគម្លាតសមត្ថភាពដែលបានរកឃើញ។ ក្រុមប្រឹក្សា និងមន្ត្រីក្រុង ស្រុកបានទទួលស្គាល់ថាការបង្កើនជំនាញរបស់គាត់នឹងអាចកែលម្អលទ្ធផលការងាររបស់ខ្លួន។

**<u>វគ្គផ្សព្វផ្សាយព័ត៌មានប្រចាំឆ្នាំ បន្ទាប់ពីមានការអនុម័តថវិកាប្រចាំឆ្នាំក្រុង ស្រុក</u>**

ចំណេះដឹងរបស់មន្ត្រីក្រុង ស្រុកជារឿយៗមានតែទៅតាមផ្នែកជាក់លាក់នៃថវិកាដែលពាក់ព័ន្ធនឹងភារកិច្ច និងតួនាទីរបស់ខ្លួនប៉ុណ្ណោះ។ ការធានាថាម្នាក់ៗមានចំណេះដឹងទូទៅទូលំទូលាយលើថវិការបស់ក្រុង ស្រុកនឹងចូលរួមចំណែកខ្លាំងទៅលើប្រសិទ្ធភាពក្នុងការអនុវត្តកាន់តែប្រសើរ។ បន្ទាប់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុម័តថវិការួច មន្ត្រី និងក្រុមប្រឹក្សាក្រុង ស្រុកទាំងអស់គួរទទួលព័ត៌មានអំពី៖ i)ចំនួនថវិកាប្រចាំឆ្នាំ ii) ខ្ទង់ចំណូល និងចំណាយ (ជំពូក គណនី និងអនុគណនី) iii) គម្រោង និងផែនការសកម្មភាពប្រចាំឆ្នាំសម្រាប់ដែនសមត្ថកិច្ចរបស់រដ្ឋបាលខ្លួន។

**<u>ការបណ្តុះបណ្តាលថវិកាសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក</u>**

- ពាក្យ និងទស្សនទានបច្ចេកទេសនៃថវិកាក្រុង ស្រុក
- ការគ្រប់គ្រង និងការអនុវត្តថវិកា

- ការរៀបចំថវិកា និងការដំណើរការអនុម័ត
- ការពិនិត្យពិច័យថវិកា

**ការបណ្ដុះបណ្ដាលថវិកាសម្រាប់ប្រធានរដ្ឋបាល/ហិរញ្ញវត្ថុ និងមន្ត្រីហិរញ្ញវត្ថុ**

- ពាក្យ និងទស្សនទានបច្ចេកទេសមានក្នុងថវិកាក្រុង ស្រុក
- ការរៀបចំសំណើថវិកា
- ការអនុវត្ត ការតាមដានថវិកា លទ្ធកម្ម រួមទាំងការទូទាត់ថវិកា
- ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុប្រើប្រាស់ដោយរដ្ឋបាលក្រុង ស្រុក

**ការបណ្ដុះបណ្ដាលស្ដីពីក្របខណ្ឌបទប្បញ្ញត្តិច្បាប់ និងគោលនយោបាយ**

នៅពេលដែលអាចបាន រដ្ឋបាលក្រុង ស្រុកចាំបាច់ធ្វើបច្ចុប្បន្នភាពអំពីការផ្លាស់ប្ដូរក្របខណ្ឌបទប្បញ្ញត្តិច្បាប់ និងគោលនយោបាយឱ្យបានត្រឹមត្រូវ រួមទាំងច្បាប់ និងសារាចរថ្មីៗ។

**ការបណ្ដុះបណ្ដាលស្ដីពីឌីជីថល**

ដូចបានលើកឡើងពីមុនមក ការលើកកម្ពស់ជំនាញឌីជីថលរបស់រដ្ឋបាលក្រុង ស្រុកមានសារៈសំខាន់ណាស់ក្នុងការប្រើប្រាស់ឧបករណ៍អនឡាញ ដើម្បីធ្វើឱ្យការប្រាស្រ័យទាក់ទងគ្នារវាងប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធកាន់តែប្រសើរឡើង។

- គ្រប់គ្រងក្រុម និងប៉ុស្ដិ៍តេឡេក្រាម
- ហ្វេសប៊ុក៖ ការបន្តផ្ទាល់ និងផ្សាយវីដេអូ ហ្វេសប៊ុកឆាត ឧបករណ៍ដើម្បីផលិតខ្លឹមសារថាមវន្ត និងទាក់ទាញ ជំរុញឱ្យគេស្គាល់ទំព័រហ្វេសប៊ុកក្រុង ស្រុក និងបង្កើនចំនួនអ្នកប្រើប្រាស់
- ការផលិតវីដេអូ
- សន្តិសុខឌីជីថល ដើម្បីធានាថាប្រព័ន្ធរដ្ឋបាលក្រុង ស្រុក និងគណនីបណ្ដាញសង្គមមានសន្តិសុខ និងសុវត្ថិភាព
- ឯកជនភាពឌីជីថល ដើម្បីធានាថាព័ត៌មានរសើប និងសម្ងាត់ត្រូវបានការពារ។

**ការបណ្ដុះបណ្ដាលបន្ថែម**

- ជំនាញភាពជាអ្នកដឹកនាំ និងជំនាញត្រួតពិនិត្យសម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក

- វគ្គបណ្តុះបណ្តាលគ្រប់គ្រងរដ្ឋបាលសម្រាប់មន្ត្រីរដ្ឋបាល រួមទាំងការគ្រប់គ្រងលិខិតចេញចូល សេចក្តីបង្គាប់ចុះបេសកម្ម និងលិខិតចុះបញ្ជីការនានា។

នៅឯសិក្ខាសាលាពិគ្រោះយោបល់នៅភ្នំពេញ មានសំណូមពរដើម្បីពង្រឹងតួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងនាមជាអ្នកផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ជាពិសេសអំពីនីតិវិធីលទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។ ក្រៅពីនេះ ក្រសួងថ្នាក់ជាតិ អាចស្នើសុំឱ្យអង្គការសង្គមស៊ីវិលផ្តល់វគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងទិន្នន័យណាមួយជាក់លាក់ ក្នុងគោលបំណងរៀបចំប្រព័ន្ធទិន្នន័យនោះឱ្យមានលក្ខណៈស្តង់ដារតែមួយដូចគ្នា ព្រោះបច្ចុប្បន្នរកឃើញថា រដ្ឋបាលក្រុង ស្រុកកំពុងប្រើប្រាស់ប្រព័ន្ធទិន្នន័យច្រើនផ្សេងគ្នា ដូចជា កម្មវិធីអ៊ិសេល (Excel) និង កម្មវិធីឃ្វីកប៊ុក (Quickbook) ជាដើម។ នេះគឺជារឿងមួយដែលគួរស្វែងយល់ និងពិភាក្សាបន្ថែមជាមួយអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធ។

### 8.4. ទម្រង់គំរូថវិកាប្រចាំឆ្នាំក្រុង ស្រុកដែលងាយយល់

ប្រជាពលរដ្ឋ មន្ត្រីក្រុង ស្រុក ក្រុមប្រឹក្សា និងតំណាងមកពីអង្គការសង្គមស៊ីវិលតែងតែយល់ស្របគ្នាថា ទម្រង់ថវិកាប្រចាំឆ្នាំបច្ចុប្បន្នដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងតែប្រើប្រាស់មានភាពស្មុគស្មាញ វែង និងពិបាកយល់ខ្លាំង។ ចេញពីគំនិត និងសំណូមពររបស់ពួកគាត់ រដ្ឋបាលក្រុង ស្រុកត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ទម្រង់ថវិកាប្រចាំឆ្នាំដែលស្នើឡើងនៅក្នុងទម្រង់ទី ២ នៃឧបសម្ព័ន្ធទី ៦។

**ទម្រង់ទី ១៖ ទម្រង់គំរូផ្លូវការប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។** ឯកសារនេះបង្ហាញអំពីទម្រង់បច្ចុប្បន្នដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំពុងប្រើ ដើម្បីជូនដំណឹងអំពីថវិកាប្រចាំឆ្នាំដល់រដ្ឋបាលក្រុង ស្រុក។ ឯកសារនេះត្រូវបានគេផ្ញើជូននៅពេលដែលថវិកាជាតិទទួលបានការអនុម័តពីរដ្ឋសភាជាតិ ព្រឹទ្ធសភាជាតិ និងឡាយព្រះហស្ថលេខារួចដោយព្រះមហាក្សត្រ។ ដូចដែលបានឃើញ នេះជាទម្រង់ទូទៅ និងស្តង់ដារដែលរួមបញ្ចូលគ្រប់ខ្ទង់ចំណូលចំណាយទាំងអស់ (ជំពូក គណនី អនុគណនី) រួមទាំងខ្ទង់ដែលមិនចាំបាច់។ ជួរវែងៗ និងមិនមានសរសេរអ្វីសោះនោះអាចធ្វើឱ្យមានភាពភ័ន្តច្រឡំ និងពិបាកយល់។

**ទម្រង់ទី ២៖ ទម្រង់គំរូដែលបានស្នើឡើងសម្រាប់រដ្ឋបាលស្រុក/ក្រុង។** រដ្ឋបាលក្រុង ស្រុកអាចប្រើប្រាស់ទម្រង់ដែលបានកែសម្រួលរួច ដោយចាប់យកព័ត៌មានដែលពាក់ព័ន្ធសំខាន់ៗពីទម្រង់ថវិកាដែល

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្ញើជូន ដើម្បីចែករំលែកអំពីថវិកាជាតិដែលបានអនុម័តរួច។ គំរូដែលបានស្នើឡើងនេះនឹងឆ្លុះបញ្ចាំងតែថវិកាចំណូលចំណាយណាមានព័ត៌មានពាក់ព័ន្ធនឹងថវិកាគម្រោង (ជំពូកគណនី និងអនុគណនី) សម្រាប់រដ្ឋបាលក្រុង ស្រុក។

ទម្រង់អក្សរប្រើប្រាស់នៅក្នុងទម្រង់គំរូមានភាពធំជាងទម្រង់បច្ចុប្បន្ន ដើម្បីឱ្យងាយស្រួលអាន។ ក្រៅពីនេះ មានក្រាហ្វិក ២៖ មួយសម្រាប់ចំណូល និងមួយទៀតសម្រាប់ចំណាយ ដើម្បីងាយមើលឃើញភ្លាមពីភាពផ្សេងគ្នានៃជំពូកនីមួយៗ។

## 9. ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** ព័ត៌មានលម្អិតរបស់ឃុំ សង្កាត់ ដែលបានជ្រើសរើសក្នុងការធ្វើអង្កេតប្រជាពលរដ្ឋ



**ឧបសម្ព័ន្ធទី២៖** ទម្រង់គំរូថវិកាដែលបានបង្ហាញដល់អ្នកផ្តល់សម្ភាសន៍ ក្រុងកំពង់ចាម (មានភ្ជាប់ជូនឯកសារ PDF មកជាមួយ)

**ឧបសម្ព័ន្ធទី៣៖** ការរចនាក្រាហ្វិកដែលបានស្នើឡើងបង្ហាញអំពីប្រភពចំណូល និងចំណាយសំខាន់ៗ ដែលយកឧទាហរណ៍ពីថវិកា ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ



**ឧបសម្ព័ន្ធទី៤៖** ឯកសារអប់រំផ្សព្វផ្សាយដែលបានបិទនៅលើក្តារព័ត៌មានសាធារណៈនៅការិយាល័យស្រុកមោងឫស្សី ដែលបានបង្ហាញអំពីជំហាននានាដែលប្រជាពលរដ្ឋត្រូវអនុវត្តក្នុងពេលទៅបោះឆ្នោត




គំរូសកម្មភាពក្នុងការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី
ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
ថ្ងៃអាទិត្យ ទី២៦ ខែឧសភា ឆ្នាំ២០១៩
គ.ជ.ប
គំរូការិយាល័យចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩

**ឧបសម្ព័ន្ធទី៥៖** ថវិកាស្រុកបាកាន ដែលផលិតដោយមានការគាំទ្របច្ចេកទេសពីវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)



**ឧបសម្ព័ន្ធទី៦៖** ទម្រង់គំរូដែលបានស្នើឡើងសម្រាប់ថវិកាប្រចាំឆ្នាំរបស់ក្រុង ស្រុក (មានភ្ជាប់ជូនឯកសារក្នុង Excel)